# អាឡវកសូត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE



ព.ស ២៥០២

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ALAVAKASŪTRA

TRADUIT DU PĀLI EN ÇAMBODGIEN

PAR

LE VÉNÉRABLE ÑĀNASAMVARA NHÉAN-CHHŒUN

MEMBRE DE LA COMMISSION DU TRIPITAKA

Cette publication a reçu l'approbation
du Conseil des Ministres et des deux Chefs de Secte

Troisième Edition 一九九八年一月三十日

星期五

PHNOM-PENH
Editions de l'Institut Bouddhique
1959

chantrangcey - pagoda

## វាក្យារម្ភ

លំនាំដើមដែលនាំបណ្ដាលឲ្យកើតសៀវភៅ (អាឡវកសូត្រនេះ ឡើង) អាស្រ័យមកពីអ្នកស្ដាប់ធម៌ទេសនាជាច្រើនរូបគឺ :

អ្នកខ្លះដែលបានស្ដាប់ធម៌នាអាថ៌ប្រស្នាក្នុងព្រះសូត្រនេះហើយ ក៏កើតបីតិជាបដល់ព្រឺរោមព្រឺក្បាលក៏មាន ។

អ្នកខ្លះមានបំណងថា ប្រសិនបើលោកអ្នកប្រាជ្ញអង្គណាបានប្រែព្រះសូត្រនេះចេញពីបាលីមកជាសម្រាយ ហើយរៀបរៀងសេចក្ដីប្រែរួចធ្វើជាសៀវភៅមួយផ្សេងដោយឡែក ដើម្បីយើងនឹងបានរកជាវយកទៅមើលសិក្សាជាការស្រួលពេក ។

អ្នកខ្លះគិតធ្វើបុណ្យ (ឈាបនកិច្ច) ឬជាសពអ្នកដ៏មានគុណ ។

អ្នកខ្លះគិតធ្វើបុណ្យសម្ពោធន៍ព្រះវិហារ...ព្រះពុទ្ធរូប.. បញ្ចុះសីមា ។

អ្នកខ្លះគិតធ្វើបុណ្យសម្ពោធន៍ចេតិយ...ហោត្រៃ សេនាសនៈតូចធំផ្សេងៗទៀត ។ លោកអ្នកទាំងអម្បាលនេះ បាននាំយកសេចក្ដីយល់របស់ខ្លួន ៗ មកប្រាប់ខ្ញុំ សូមឲ្យខ្ញុំជ្រើសរើសយកស្រង់ធម៌អាថ៌ពីគម្ពីរព្រះត្រៃ-បិដកត្រង់រឿងណាមួយមកបកប្រែរៀបរៀងជាសេចក្ដី ហើយបោះពុម្ពជាសៀវភៅឡើង, សឹមយើងខ្ញុំរៃអង្គាសគ្នាជាថ្លៃពុម្ពតាមគួរនឹងផលខ្លួនប្រយោជន៍, លុះបានទទួលយល់ព្រមហើយ ក៏ខ្ញុំព្យាយាមប្រែ(អាឡវកសូត្រ)

នេះ ចេញពីគម្ពីរសំយុត្តនិកាយ, សគាថវគ្គ, ត្រង់យក្ខសំយុត្តព្រមទាំង
អដ្ឋកថានៃគម្ពីរនោះផង, គម្ពីរដីកាពាហុំផង ពីគម្ពីរផ្សេង ៗ ដែលជាប់ទាក់
ទងគ្នា មកប្រែនិងរៀបរៀងជាសេចក្តីនេះ, កាលកំពុងប្រែនិងរៀបរៀង
នោះក៏នឹកមើលថា រឿងនេះមានសេចក្តីប្រែរាយ ដែលជាស្នាដៃរបស់លោក
អ្នកប្រាជ្ញពីបុរាណខ្លះហើយដែរ តែនៅមិនទាន់បរិបូណ៌ សាយភាយដល់
អ្នករៀនអ្នកស្តាប់ទេ ព្រោះមាននៅតែរោយវត្តមួយ ៗ បើទុកជាមានទៀត
សោតក៏ជារបស់ល្បៀងឃ្លាត ស្ទើរតែនឹងស្តាប់សេចក្តីពុំបាន, ព្រោះអ្នក
ចារចំឡងតៗ គ្នាមកភ្លាត់ច្រើនដំណរហើយ ។

មួយវិញទៀត ធម៌អាថ៌ក្នុងព្រះសូត្រនេះងាយស្តាប់ ងាយមើល
ងាយចាំស្រួលណាស់, សេចក្តីមិនគ្រោតគ្រាតពេក មិនល្អិតពេក សមគួរ
តាមកំឡាំងសតិបញ្ញារបស់កុលបុត្ត ដែលនៅមានបញ្ញាទន់ខ្សោយនៅឡើយ ។

លុះរៀបរៀងបានជាងពាក់កណ្តាលហើយ ដឹងថាជាការប្រញាប់ពេក
នឹងធ្វើម្នាក់ឯងមិនទាន់ការ ខ្ញុំក៏បានឲ្យលោកអាចារ្យ ( ខុក ជា ) ក្រុមជំនុំ
ប្រែព្រះត្រៃបិដក ជួយប្រែនិងរៀបរៀងបញ្ចប់ឲ្យ; លុះចប់រួចហើយ ខ្ញុំក៏
បានពិនិត្យសេចក្តីនេះផ្ទាល់ខ្លួនឯងទៀត ឃើញសមតាមបាលីនិងអដ្ឋកថា
ល្មមស្តាប់សេចក្តីបានហើយ ទើបខ្ញុំនាំយកទៅប្រគេនព្រះតេជព្រះគុណ
ព្រះសិរីសម្មតិវង្សប្រធានសាលាបាលីជាន់ខ្ពស់, អធិបតីក្រុមជំនុំប្រែព្រះ

ត្រៃបិដក, ស៊ីហ៍លីយេ ដើម្បីឲ្យស្រួនជួរណ៌ ព្រះនាម (ឯម) សូមឲ្យលោកពិនិត្យសម្រេចថែមទៀតឲ្យទាន់; លោកក៏បានពិនិត្យឲ្យទាន់តាមសូម ។

ក្នុងទីបំផុតនេះ: សូមអ្នកដែលបានអានបានមើលសៀវភៅនេះ កុំប្រញាប់សោយបាកញ្ញាយាមដោយទ្រាន់នឹងពាក្យផ្ដាំផ្គើ ឬទ្រាន់នឹងសេចក្ដីដែលខ្លួនបានស្គាល់ជំនាញហើយពីមុនៗទៀយ សូមជៀបនឹងអ្នកដែលទទួលទានអំពៅសិន គង់អាចនឹងប្រាប់បាន ព្រោះធម៌អាថ៌ក្នុងសៀវភៅនេះរៀបរៀងរឿងនិទានជាមុន ទើបរៀបរៀងធម៌អាថ៌ជាខាងក្រោយ ដូចនឹងមាននៅក្នុងភាគមុខនេះ ។

សូមផ្សាយកុសលរាសីរបស់ធម្មទាននេះ ចែកជូនដល់ពពួកបុព្វបុរសគ្រប់ជាន់គ្រប់ថ្នាក់, ចែកជូនដល់ពពួកឥស្សរជនដែលជាក្រុមសម្មតិទេពគ្រប់ៗដំណែង, ចែកជូនដល់ពពួកឧបបត្តិទេពក្នុងអនន្តចក្រវាឡ, ចែកជូនដល់អ្នកដែលបានផ្ដួចផ្ដើមឲ្យកើតឡើងជាសៀវភៅនេះ សូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផល តាមប្រាថ្នា, ទាំងកុលបុត្រដែលជាអ្នកបានស្ដាប់បានអានមើល បានសិក្សាធម៌អាថ៌នេះ សូមឲ្យលូតលាស់ដុះដាលចំរើនក្នុងព្រះពុទ្ធសាសនាចិរដ្ឋិតិកាលតរៀងទៅ ។

ព្រះគ្រូញាណសំវរ ញាណ-ឈឹន

ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀងជាសេចក្ដី ។

# មាតិកានុក្រម


ទំព័រ

១_ នមស្សការ ----------------------------------------------១

២_ រឿងព្រះបាទអាឡវីរាជ ---------------------------------------៣

៣_ គ្រឿង៩ប្រការ -------------------------------------------២០

៣_ អំពីអាវុធ ៤ប្រការ ----------------------------------------២៣

៥_ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឱ្យអាឡវកយក្សសួរប្រស្នា -----៣០

៦_ អំពីប្រស្នាដែលអាឡវកយក្សសួរ ----------------------------៣១

៧_ ព្រះដ៏មានព្រះភាគទ្រង់វិស្សជ្ជនាប្រស្នា ----------------------៣២

៨_ ប្រស្នាទី១ អំពីសទ្ធា ( ធ្ងន់អធ្ងន់ទាំងបួន ) -----------------៣២

៩_ ប្រស្នាទី ២អំពីធម្មៈ ---------------------------------------៣៧

១០_ ប្រស្នាទី ៣សច្ចៈ ----------------------------------------៣៨

១១_ ប្រស្នាទី ៤ អំពីបញ្ញា ------------------------------------៤២

១២_ គាថាទី ២ អំពីសេចក្ដីសួររបស់អាឡវកយក្ស ----------------៤៧

១៣_ ព្រះដ៏មានព្រះភាគទ្រង់តបជាបទព្រះគាថាវិញ ---------------៤៧

១៤_ អធិប្បាយប្រស្នា ៥បទ ---------------------------------------៤៨

១៥_ ព្រះដ៏មានព្រះភាគ ---------------------------------------៦៩

## នមស្ការ

យោ អគ្គបុគ្គលោ ពុទ្ធោ អាទរេន នមាមិ តំ
ធម្មំ សង្ឃំ អថោ តស្ស សុត្តំ ភាសិ សមាសតោ ។

ព្រះសម្ពុទ្ធជាម្ចាស់អង្គណា ទ្រង់ប្រសើរផុតលើសសត្វលោក, ខ្ញុំសូមនមស្ការចំពោះព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ ដោយគោរព; មិនតែប៉ុណ្ណោះ ខ្ញុំសូមនមស្ការចំពោះព្រះធម៌ផង, ព្រះសង្ឃផង, របស់ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ, ហើយនឹងសូមថ្លែងនូវអាឡវិកសូត្រដោយសង្ខេប ក្នុងកាលឥឡូវនេះ ។

## អាឡវិកសូត្រ

ឯវំមេ សុតំ អាឡវិកសូត្រនេះ ខ្ញុំឈ្មោះអានន្ទបានស្ដាប់មកយ៉ាងនេះថា ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថក្នុងមន្ទីររបស់អាឡវិកយក្ស ជិតក្រុងអាឡវី(១) ។

គ្រានោះ អាឡវិកយក្ស(២) ចូលទៅរកព្រះដ៏មានព្រះភាគ, លុះចូល

---

១ ទីក្រុងនេះហើយដែលព្រះសម្ពុទ្ធទ្រង់បញ្ញត្តភូតគាមសិក្ខាបទ ថា « ភិក្ខុធ្វើភូតគាមមានដើមឈើនិងវល្លិ៍ជាដើម ដែលកើតដែលដុះលើផែនដី ឬទីណាមួយ ឲ្យដាច់រលេះរដកកម្រើកឃ្លាតចាកទី ត្រូវបាចិត្តិយៈ » ។ ២ គឺយក្សនេះហើយដែលមានរឿងដំណាលថា « ធ្វើចម្បាំងនឹងព្រះអង្គអស់រហូត ១ រាត្រី ទ្រង់ឈ្នះយក្សដោយខន្តីបារមី នាក្រោយបឋមពោធិកាល, ក្នុងពុទ្ធជយមង្គល, ត្រង់គាថាទី ២, មាននិទានក្នុងដីកាពាហុំ » ។

ទៅដល់ហើយ ទើបពោលពាក្យបង្គាប់ថា នែសមណៈ អ្នកចូរចៀសចេញ; ព្រះដ៏មានព្រះភាគទ្រង់ទទួលថា ល្អហើយ ៗ ព្រះអង្គក៏ចៀសចេញទៅ បង្គាប់ថាឲ្យចូលមក ព្រះអង្គក៏ចូលមក អាឡវកយក្សពោលពាក្យបង្គាប់ឲ្យព្រះអង្គចៀសចេញទៅ នឹងចូលមកវិញតែយ៉ាងនេះ ជាគម្រប់ ២ ដង ៣ ដង; ព្រះអង្គក៏ធ្វើតាមពាក្យបង្គាប់នោះ ឥតរឹងទទឹងឡើយ, លុះដល់វារៈ ជាគម្រប់ ៤ ដង ៗ ព្រះអង្គប្រកែកមិនព្រមធ្វើតាមឡើយ, ហើយទ្រង់តបថា តថាគតមិនចៀសចេញទៅ មិនចូលមកវិញទៀតទេ បើអ្នកចង់ធ្វើអ្វីក៏ធ្វើតាមចិត្តចុះ ។

អាឡវកយក្សក៏តបថា ខ្ញុំនឹងសួរប្រស្នាចំពោះព្រះអង្គ, បើព្រះអង្គមិនដោះប្រស្នាខ្ញុំទេ, ខ្ញុំនឹងធ្វើព្រះហឫទ័យរបស់ព្រះអង្គឲ្យវាយមាយ ឬនឹងវិះបេះដូងរបស់ព្រះអង្គឲ្យដាច់ខ្ទាតខ្ចាយ, ឬក៏នឹងចាប់ជើងគ្រវែងទៅត្រើយទន្លេគង្គាខាងនាយ ជាមិនខានឡើយ ។

ព្រះអង្គទ្រង់តបថា នែអាឡវកយក្ស ក្នុងលោកទាំងមូល ព្រមទាំងទេវលោក, មារលោក, ព្រហ្មលោក, ក្នុងពពួកសត្វ, ព្រមទាំងសមណៈនិងព្រាហ្មណ, ទាំងទេវតានិងមនុស្សជាសាមញ្ញ ឥតមានបុគ្គលណាមួយ អាចនឹងធ្វើចិត្តរបស់តថាគតឲ្យវាយមាយ ឬនឹងវិះ

ពេះដូង ឬកនឹងចាប់ដើមតថាគតត្រូវជង់ទៅត្រើយទន្លេគង្គាខាងនាយបាន ទឡ្ហើយ, តែថាល្មើយចុះ បើអ្នកចង់សួរអ្វីសួរចុះតាមត្រូវការ ។

(និទានកថាក្នុងបាលីអស់សេចក្តីតែត្រឹមនេះ តពីនេះនឹងរៀបរៀង ឧប្បត្តិហេតុនៃអាឡវកយក្ស តាមបរិយាយក្នុងអដ្ឋកថាជាមុនសិន, សឹម រៀបរៀងប្រស្នា ដែលអាឡវកយក្សសួរជាខាងក្រោយតទៅ ។

ឯអាឡវកយក្សនេះហើយ ដែលល្បីឈ្មោះថាជាយក្សរបើងរឹងរូស ក្រៃលែងជាងក្រុងមារាធិរាជ (១), ព្រះអង្គទ្រង់ច្បាំងរហូតអស់មួយរាត្រី ទើបបានឈ្នះយក្ស ដោយខន្តិបារមី ក្នុងកាលដ៏ពេលនោះ) ។

មានសេចក្តីដំណាលថា កាលក្នុងជំនាន់នោះ មានក្សត្រិយ៍មួយអង្គ នាមព្រះបាទអាឡវីរាជ សោយរាជ្យក្នុងក្រុងអាឡវី, សម័យមួយ ស្តេចចេញទៅពីក្រុង ដើម្បីនឹងការពារបរខ្មាំងជិត, ការពារពួក ចោរមិត្រពីប្រទេសក្រៅដែន, ធ្វើព្យាយាមនឹងហាត់កំឡាំងកាយព្រះអង្គ ផង ។ លុះចេញទៅបាន ៧ថ្ងៃ ស្តេចទៅក្រសាលទ្រង់ព្រាននឹងប្រពាត ម្រឹគ ទើបទ្រង់ដាក់កម្រិតព្រះរាជអាជ្ញាថា « បើម្រឹគរត់ចេញត្រង់មុខ

---

១ គឺយក្សនេះហើយដែលមានរឿងដំណាលថា «ធ្វើសង្គ្រាមនឹងព្រះអង្គ ៗ ទ្រង់ឈ្នះយក្ស ដោយខន្តិបារមី តាមគាថាបឋមពោធិកាល, ក្នុងពុទ្ធជយមង្គលត្រង់គាថាទី ១, មានពិស្តារក្នុងដីកាពាហុំ» ។

អ្នកណា ត្រូវតែអ្នកនោះទទួលភារៈជាទម្ងន់អញ្ជាលើខ្លួន» ថា ហើយព្រះអង្គក៏ទ្រង់ផ្ចង់ដោយព្រះអង្គឯង ។

គ្រានោះ មានម្រឹគព្រាយមួយ ភិតភ័យស្លាយជីវិត ក្រឡេកមើលទិចខ្ទោះនឹងគេចវេះ ក៏ឃើញចន្លោះត្រង់ព្រះភក្ត្រព្រះបាទអាឡវីរាជ ហើយក៏គេចបោលចេញទៅត្រង់ចន្លោះនោះ, ព្រះអង្គក៏ស្ទុះដេញតាមទាន់បាញ់ម្រឹគនោះបាន ហើយទ្រង់អារកាត់ពន្លះយកសាច់មកវែងចែកជាពីរចំណែក ធ្វើអំរែករែកលើព្រះអង្សាត្រាច់ទៅ, ស្រាប់តែទ្រង់បានឃើញដើមជ្រៃ ១ ដើម មានម្លប់ត្រឈៃ មានមែកត្រសុំត្រសាយ, ស្ដេចក៏ចូលទៅឈប់សម្រាកព្រះកាយក្រោមម្លប់ជ្រៃ ដែលជាអាណាខេត្តរបស់អាឡវកយក្ស, ឯអាឡវកយក្សបានមន្ទីរនេះព្រមទាំងអាជ្ញា ដែលគួរចាប់យកអ្នកដំណើរ ឬសត្វតូចធំស៊ីជាចំណីបាន អំពីសំណាក់ស្ដេចចាតុម្មហារាជទាំង ៤, តាំងពីគ្រានោះដរាបមក តែងនឹងចាប់យកអ្នកដំណើរខ្លះ, សត្វតូចធំខ្លះ ដែលចូលទៅក្នុងម្លប់ជ្រៃស៊ីជាចំណីរបស់ខ្លួនតាមធម្មតា, ក្នុងវេលានោះ យក្សបានឃើញព្រះបាទអាឡវីរាជ ស្ដេចចូលទៅដល់ម្លប់ជ្រៃហើយ, ក៏ស្ទុះមកចាប់ព្រះអង្គប្រុងនឹងស៊ីជាចំណីដូចគ្រាមុនៗ ព្រះអង្គក៏អង្វរយក្សថា នែយក្ស អ្នកចូរលែងយើងចុះ យើងនឹងបញ្ជូនមនុស្សម្នាក់នឹងបាយមួយភាជនៈមកឲ្យអ្នករាល់ៗថ្ងៃ តាំង

ពីថ្ងៃស្អែកនេះរៀងទៅ, យក្សតបថា ក្រែងអ្នកបានរួចពីដៃយើងហើយ អ្នកសប្បាយនឹងស្រីស្នំរបស់អ្នក ៗ ភ្លេចពាក្យសំដីរបស់ខ្លួន បែរទៅជាមិនបញ្ជូនមនុស្សនឹងបាយមកឲ្យយើងទេដឹង? ចំណែកខាងយើងត្រូវការតែស៊ីអ្នក, ព្រោះអ្នកបានចូលមកដល់អាណាខេត្តរបស់យើង ៗ មិនមានអំណាចនឹងចាប់យកមនុស្ស ដែលមិនមានអនុញ្ញាតមកស៊ីជាចំណីបានឡើយ, យើងឈ្នះអ្នកហើយ, យើងមិនត្រូវការលែងអ្នកឲ្យរួចទៅទេ ។

ព្រះបាទអាឡវីរាជ ស្ដេចក៏អង្វរទៀតថា នែយក្ស បើប្រសិនជាយើងភ្លេចមិនបានបញ្ជូនមកថ្ងៃណាមួយ, ឲ្យអ្នកទៅកាន់មន្ទីរយើង ហើយចាប់យើងស៊ីក្នុងថ្ងៃនោះចុះ យើងឥតប្រកែកឡើយ ។

មួយវិញទៀត បើអ្នកស៊ីយើងហើយវានឹងល្បីខ្ចរខ្ចាយទៅនានានគរ, អ្នកនគរឯទៀត ៗ កាលបើគេដឹងថានៅដើមជ្រៃឯណោះ ៗ មានយក្សកាចចាំចាប់មនុស្សស៊ីជាចំណីដូច្នោះ គេក៏លែងហ៊ានដើរមកដល់កន្លែងរបស់អ្នក ៗ នឹងសាបសូន្យខាតលាភធំតាំងពីថ្ងៃនេះទៅ, យក្សបានស្ដាប់ពាក្យអង្វរនឹងពាក្យបំភ័យដូច្នោះហើយ ក៏លែងស្ដេចអាឡវីរាជទៅក្នុងពេលនោះ, ព្រះអង្គក៏ត្រាច់សំដៅទៅកាន់នគររបស់ព្រះអង្គទៅ ។

ឯពួកពលនិកាយ ដែលបោះកងទ័ពនៅជុំព្រះអង្គក្នុងពាក់កណ្ដាលផ្លូវឆ្ងាយរួចហើយនុះ លុះឃើញស្ដេចមកដល់ហើយ ទើបនាំគ្នា

ក្រោកឡើងទទួលគំនាប់ក្រាបបង្គំទូលសួរប្រវត្តិហេតុ ដែលព្រះអង្គដេញតាមម្រឹគនោះ; ព្រះអង្គក៏ថ្លែងប្រាប់ប្រវត្តិហេតុរៀបរាប់សព្វសេចក្តី, ដូចពណ៌នាមកហើយពីខាងដើម , ពួកពលក៏ហោមរោមហែព្រះអង្គចូលទៅកាន់ទីក្រុង, លុះស្តេចបានដល់ទីក្រុង ហើយព្រះក្រយាហាររួចហើយ ទើបទ្រង់ត្រាស់ហៅនគរគុត្តិកបុរស (នាយគុក) មកថ្លែងព្រះរាជឧត្តារប្រាប់ហេតុនោះដូចមុន ។

នគរគុត្តិកបុរស ក្រាបបង្គំទូលសួរថា បពិត្រព្រះសម្មតិទេព ចុះព្រះអង្គបានកំណត់ប៉ុណ្ណោះថ្ងៃ ប៉ុណ្ណោះខែដែរឬទេ? ។

ស្តេចទ្រង់ត្រាស់ថា ទេ យើងឥតមានកំណត់ថ្ងៃខែទេ ។

នគរគុត្តិកបុរស ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បើព្រះអង្គមិនកំណត់ថ្ងៃខែយ៉ាងនេះ ជាការក្រមណាស់, ព្រោះពួកមនុស្សទាំងអស់ បានតែកំណត់ថ្ងៃខែឲ្យហើយទើបងាយ កាលបើមិនមានកំណត់ថ្ងៃខែហើយ នឹងទៅជាការបៀតបៀនដល់បណ្តាជន ដែលនៅក្នុងដែនទាំងមូលឲ្យបានសេចក្តីទុក្ខលំបាកជាយូរអង្វែង, និងជាហើយចុះ សូមព្រះអង្គកុំខ្វល់ខ្វាយក្នុងរឿងនោះឡើយ សូមទ្រង់រាជ្យជាសុខសម្រាន្តទៅចុះ, ទូលព្រះបង្គំជាខ្ញុំនឹងចាត់ចែងថ្វាយតាមការគួរ, ហើយទើបនគរគុត្តិកបុរសទៅឈរនៅមាត់ទ្វារគុកពីព្រលឹម ហើយចាត់ចែងថា មនុស្ស

ទោសប៉ុណ្ណោះនាក់ត្រូវសម្លាប់ ប៉ុណ្ណោះនាក់ត្រូវដោះលែង មនុស្សទោសណាដែលត្រូវសម្លាប់ជាមុន, ក៏នាំយកមនុស្សទោសនុះទៅឯព្រះដំណាក់ ឲ្យងូតទឹកទទួលទានភោជនាហារ រួចហើយបង្គាប់ថា “អ្នកត្រូវយកភោជន ១ ភាជនៈនេះទៅឲ្យយក្សត្រង់ដើមជ្រៃឯណោះ ៖”

ឯយក្សក៏និម្មិតអត្តភាពធំសម្បើមគួរឲ្យខ្លាច; លុះមកចាប់បុរសអ្នកទោស ដែលចូលទៅដល់ដើមជ្រៃនោះ ហើយបរិភោគព្រមទាំងភោជន ១ ភាជនៈផង, គួរនាមដូចបុរសអ្នកបរិភោគមើមដំឡូងដូច្នោះ ។

ក្នុងគល់ដើមជ្រៃធំនោះ ក៏ដេរដាសពាសពេញទៅដោយសរីរៈរបស់មនុស្សមានសាច់ឈាមជាដើម, គរជាគំនរស្អិតជាប់ៗគ្នាដូចដុំនវនីត(១) ដោយអំណាចយក្សបរិភោគតែយ៉ាងនេះ ។

លុះយូរមក ពួកមនុស្សបានឃើញយក្សបរិភោគមនុស្សទោសនឹងភោជនដែលស្តេចបញ្ជូនទៅឲ្យ ក៏ភ័យតក់ស្លុត រត់មកប្រាប់ញាតិមិត្តរបស់ខ្លួនទីទៃៗថា តាំងពីព្រឹមថ្ងៃនេះទៅ ស្តេចនឹងបញ្ជូនពួកចោរអ្នកទោសទៅឲ្យយក្សស៊ីជាអាហារហើយ, អ៊ើះហើយពួកមនុស្សដែលនៅក្នុងដែនអាឡវីក៏លែងប្រព្រឹត្តធ្វើចោរកម្មទាំងអស់គ្នា; មិនយូរប៉ុន្មានផង គុកក៏ស្ងាត់ឥតមានមនុស្សទោសនោះ, ដោយហេតុចោរថ្មីក៏មិនមាន

១ ទឹកដោះខាប់ ។

ចូលមក, ចោរចាស់ក៏អស់សូន្យទៅជាលំដាប់; ទើបនគរគុត្តិកបុរស យកសេចក្ដីក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវនេះ មនុស្សទោសអស់រលីងទៅហើយ ។

ទើបព្រះបាទអេឡារីកជ ស្ដេចទ្រង់បង្គាប់ឲ្យចំណាយព្រះរាជទ្រព្យព្រះរាជទានទូទៅតាមលំដាប់តាមនិគមជនបទរាជធានី ដែលជាអាណាខេត្តរបស់ព្រះអង្គថា បើនរណាមួយ អាចហ៊ានប្រថុយជីវិតខ្លួនឲ្យទៅជាចំណីយក្ស ក៏ចូរកាន់យកទ្រព្យមានប្រមាណប៉ុណ្ណោះចុះ; សូម្បីព្រះអង្គទ្រង់ប្រទានព្រះរាជទ្រព្យដល់ម្ល៉ោះ, ក៏គង់ឥតមានជនណាមួយនឹងប្រាថ្នាទ្រព្យសម្បត្តិនោះផងម្នាក់ឡើយ; ទើបទ្រង់មានព្រះរាជឱង្ការត្រាស់ប្រាប់ដល់ពួកមហាមាត្យៗក៏ទទួលព្រះរាជឱង្ការថា ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នានឹងចាត់ចែងបញ្ជូនមនុស្សចាស់ជរា មួយថ្ងៃម្នាក់ៗតាមលំដាប់ត្រកូលរៀងៗទៅ; ព្រោះមនុស្សចាស់ សុទ្ធតែតាំងនៅក្នុងប្រធាននៃសេចក្ដីស្លាប់ជាធម្មតាស្រាប់; ស្ដេចមិនយល់ព្រមឡើយ ហើយទ្រង់ត្រាស់ថា ពួកមនុស្សក្នុងដែនទាំងមូល កើតចលាចលជ្រួលជ្រើមថា ស្ដេចទ្រង់បញ្ជូនមាតាបិតាយើងនឹងឪពុកធំម្ដាយធំយើង ជីដូនជីតាយើង ទៅឲ្យយក្សស៊ី ម្ល៉ោះហើយនឹងជាការនាំមិនឲ្យសម្រេចប្រយោជន៍ទេ; អ្នកទាំងអស់កុំយល់ដូច្នោះឡើយ ។ ពួកមហាមាត្យ ក្រាបបង្គំទូល

ទៀតថា សូមទ្រង់ព្រះមេត្តាប្រោសមើលចុះ នឹងបញ្ជូនទារកតូច ៗ ដែលនៅមិនទាន់ចេះអង្គុយ ; ព្រោះទារកតូច ៗ មិនទាន់ដឹងស្គាល់មាតាបិតាច្បាស់លាស់នៅឡើយ ; ព្រះអង្គក៏ទ្រង់អនុញ្ញាតយល់ព្រម ហើយ ទ្រង់បញ្ជូនព្រះរាជអាជ្ញាទៅគ្រប់តំបន់ តាមសេចក្ដីដែលទ្រង់យល់ព្រមនោះ ។

ឯចំណែកពួកស្ត្រីជាមាតាទារក ដែលប្រសូតហើយថ្មីៗក្ដី, ពួកស្ត្រីដែលកំពុងមានគភ៌ក្ដី បានដឹងហេតុនោះហើយ ក៏នាំគ្នាពុនជញ្ជូនបៅ រត់ចេញពាក់ពួនជាពួកជាកង ទៅនៅឯប្រទេសក្រៅទៅ; ពួកមហាមាត្យតែងរកចាប់បញ្ជូនទៅតែយ៉ាងនេះអស់រវាង ១២ ឆ្នាំ; លុះសម័យជាខាងក្រោយមក ពួកមហាមាត្យចាប់ទារកមិនបានដល់មកសោះ ក៏យកសេចក្ដីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឥឡូវនេះ រកចាប់ទារកមិនបានទេ, ឃើញនៅមានតែអាឡវីចកុមារ ដែលជាព្រះរាជបុត្រព្រះអង្គ ក្នុងព្រះបរមរាជវាំងមួយព្រះអង្គប៉ុណ្ណោះ ។

ស្ដេចទ្រង់ត្រាស់ថា "ព្រះរាជបុត្រជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញដូចម្ដេចមិញ , សត្វលោកទាំងពួង គង់ស្រឡាញ់ជីវិតរបស់ខ្លួនដូច្នោះដែរ បើដូច្នោះអ្នកទាំងឡាយចូរចាប់យកព្រះរាជបុត្ររបស់អញទៅឲ្យយក្ស ហើយរក្សាជីវិតរបស់អញចុះ ។

រឿងនេះហើយ ដែលគួរយល់ច្បាស់ដល់ព្រះពុទ្ធដីកាត្រង់បទថា នត្ថិ អត្តសមំ បេមំ «ស្រឡាញ់របស់អ្វីមិនស្មើនឹងស្រឡាញ់ខ្លួនឡើយ» ។

ជួនជាសម័យនោះ ព្រះរាជទេវី ដែលជាព្រះជននីនៃអាឡវីរាជ-កុមារ កំពុងតែផ្ងូតទឹកធ្វើប្រដាប់រួចហើយ ផ្ទេកលើគម្រាលសំពត់ទុកុល-ពស្ត្រ(១) បីស្ងួយផ្ទេកលើព្រះឧរាហើយអង្គុយនៅជាសុខស្រួល, ស្រាប់តែរាជបុរសទៅថ្លែងព្រះរាជអាជ្ញា ហើយចាប់យកអាឡវីរាជកុមារនាំទៅ; សូម្បីព្រះនាងទេវីជាមាតាព្រមទាំងស្រីស្នំទាំង ១៦ ពាន់នាក់, នឹងពួកមេនយំសោកអង្វរដូចម្តេចក្តី, ក៏គង់ពួករាជបុរសមិនឈប់បង្អង់ឡើយ, បម្រុងនឹងចាត់ការបញ្ជូនទៅឲ្យយក្សក្នុងថ្ងៃស្អែក ។

ក៏ក្នុងថ្ងៃនោះឯង ព្រះដ៏មានព្រះភាគទ្រង់តើនឡើង ក្នុងវេលាបច្ចូសសម័យ(២) ទ្រង់ចូលមហាករុណាសមាបត្តិ(៣) នាគន្ធកុដី ក្នុងព្រះជេតវនារាម ហើយទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញ

១ សំពត់វិសេសមួយយ៉ាង ដែលធ្វើ ដោយសម្បកឈើ អនុលោមចូលក្នុងសំពត់សាណៈ (អភិធាន) ។ ២ បច្ចូសៈ ទិ. បច្ចូសេតិ-តិមិរន្តិ, បច្ចូសោ (សមយោ) «សម័យ» កំចាត់បង់«ងងឹត» (បច្ចូសសម័យ) អភិធានប្បទីបិកាសូចិ ។ ៣ សមាបត្តិដែលមានករុណាព្រហ្មវិហារជាបុព្វប្បយោគ ។

យល់ឃើញខុសបនិស្ស័យនៃអនាគាមិផល របស់អាឡវីរាជកុមារផង, នៃសោតាបត្តិផលរបស់យក្សផង, នៃសោតាបត្តិមគ្គផលរបស់ប្រជុំជនចំនួន ៨ ម៉ឺន ៤ ពាន់នាក់ ក្នុងទីប្រជុំនៅវេលាដែលចប់ធម៌ទេសនានោះផង លុះព្រឹកឡើង ស្ដេចទ្រង់បិណ្ឌបាតធ្វើភត្តកិច្ចស្រេច ទ្រង់បំពេញពុទ្ធកិច្ចតាមធម្មតា តាំងពីត្រឹមព្រះអាទិត្យអស្ដង្គតទៅ រហូតដល់វេលាព្រលប់ ទ្រង់ពុទ្ធដំណើរទៅតាមផ្លូវមានចំងាយ ៣០ យោជន៍ (១) តែមួយព្រះអង្គឯង សំដៅទៅកាន់ពិភពយក្ស ក្នុងថ្ងៃឧបោសថខាងរនោចនាគ្រានោះ ។

ព្រោះហេតុនោះ បានជាមានសេចក្ដីក្នុងព្រះសូត្រនេះថា ព្រះអង្គគង់នៅក្នុងវិមានរបស់អាឡវកយក្សដូច្នេះឯង ។

មានពាក្យសួរថា "វិមានរបស់យក្សនៅត្រង់ដើមជ្រៃណា, ព្រះអង្គស្ដេចចូលទៅត្រង់ដើមជ្រៃនោះឬមួយស្ដេចគង់នៅត្រង់វិមានរបស់យក្ស"?

---

១ ពាក្យថា យោជន៍ ៗ នោះ គឺឈ្មោះនៃរង្វាស់មួយយ៉ាងប្រវែង ៨ ពាន់ព្យាម គឺ ១ យោជន៍ប្រវែង ៤ គាវុត, ១ គាវុតប្រវែង ៨០ ឧសភៈ; ១ ឧសភៈប្រវែង ២៥ ព្យាម (ប្រហែល ១៤ គីឡូម៉ែត្រ) ។ តាមសៀវភៅដែលនិយាយពីព្រះពុទ្ធសាសនារបស់លោកល្វីហ្វីណូតនិយាយថា យោជន៍មាន ២ គឺ យោជន៍វែងស្មើនឹង ៩ ម៉ីល ឬ ១៤ គីឡូម៉ែត្រដែលទំលាប់ប្រើក្នុងស្រុកឥណ្ឌៀសម្រាប់ហោរា; យោជន៍ខ្លីស្មើនឹងកន្លះយោជន៍មុនគឺ ៤ ម៉ែលកន្លះ ឬ ៧ គីឡូម៉ែត្រ ប្រើដោយចំណែកក្នុងដែនមគធៈ ហើយប្រើជាញឹកញយជាងគេក្នុងគម្ពីរព្រះពុទ្ធសាសនា ។

ពាក្យឆ្លើយថា "ព្រះអង្គនៅក្នុងវិមានរបស់យក្សជាពិត" ពួកយក្សតែងឃើញវិមានរបស់ខ្លួនយ៉ាងណាមិញ, ព្រះដ៏មានព្រះភាគជាម្ចាស់តែងទ្រង់ទតឃើញវិមានរបស់យក្សដូច្នោះដែរ; ព្រះអង្គស្តេចទ្រង់ពុទ្ធដំណើរទៅដល់ហើយ ទ្រង់ស្ថិតនៅមាត់ទ្វារវិមានរបស់អាឡវកយក្សនោះ ។

ក៏ក្នុងសម័យនោះ អាឡវកយក្សមិននៅឯទីកន្លែងនោះឡើយ, មានកិច្ចចូលទៅកាន់ទីប្រជុំរបស់យក្សឯហិមវន្ត : នៅតែគទ្រភយក្សដែលជានាយទ្វារចាំយាមវិមាននោះ លុះគទ្រភយក្សបានឃើញព្រះដ៏មានព្រះភាគហើយ ក៏ស្ទុះទៅថ្វាយបង្គំទូលសួរថា "បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ព្រះអង្គស្តេចទ្រង់ពុទ្ធដំណើរមកក្នុងវេលាវិកាលដូច្នេះ តើដោយមានហេតុអ្វី" ?

ព្រះសម្ពុទ្ធទ្រង់មិនទាន់ប្រាប់ហេតុទេ គ្រាន់តែទ្រង់ទទួលថា "អើគទ្រភៈ តថាគតមកដល់អម្បាញ់មិញនេះឯង, អើគទ្រភៈ ប្រសិនបើវិមាននេះនៅទូលាយមិនជាចង្អៀតចង្អល់ណាស់ណាទេ, គួរតែតថាគតឈប់សម្រាកក្នុងរាត្រីនេះផង តើបានឬទេ" ?

គទ្រភៈយក្សក៏ក្រាបបង្គំទូលថា "បពិត្រព្រះសុគតដ៏ចំរើន មិនចង្អៀតទេ ល្មមស្តេចនឹងឈប់សម្រាកនៅបាន, តែថាអាឡវកយក្សគេមិន

នៅ, យក្សនោះរឹងរូសពេកណាស់, សូម្បីតែមាតាបិតារបស់ខ្លួនក៏មិនគោរពកោតក្រែងផង, សូមព្រះអង្គកុំទ្រង់សព្វព្រះហឫទ័យនឹងឈប់សម្រាកនៅទីនេះឡើយ" ។ ព្រះអង្គទ្រង់ត្រាស់ថា "អើគទ្រភៈ តថាគតដឹងហើយថា ប្រសិនបើតថាគតនៅឈប់សម្រាកក្នុងវិមាននេះ, ឥតមានអន្តរាយអ្វីមួយមកប៉ះពាល់ដល់តថាគតទេ, ត្រូវអ្នកឲ្យតថាគតនៅឈប់សម្រាកក្នុងរាត្រីយប់នេះចុះ" ។

យក្សនាយទ្វារ ក្រាបបង្គំទូលជាគំរប់ពីរដងទៀតថា "បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន អាឡវកយក្សនេះ តែក្រោធខឹងកាលណា ក៏ក្តៅធួលប្រហែលដូចអង្គើរ ដែលភ្លើងកំពុងឆេះ, មិនស្គាល់ថាមាតាបិតា សមណព្រាហ្មណ៍ ឬមិនដឹងធម៌មិនដឹងអាថ៌អ្វីទេ, តែងធ្វើចិត្តអ្នកទាំងពួង ដែលបានជួបប្រទះឲ្យរាយមាយទៅជាឆ្កួត; ឬវះបេះដូងរបស់អ្នកទាំងនោះឲ្យដាច់ខ្ទាតខ្ចាយ ឬក៏ចាប់ជើងគ្រវែងចោលទៅត្រើយសមុទ្រខាងនាយក៏សឹងមាន, ដល់កណ្តាបចក្រវាឡខាងនាយក៏សឹងមាន តាមកំហឹងរបស់ខ្លួន" ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ជាគំរប់បីដងទៀតថា "អើគទ្រភៈ តថាគតដឹងហើយ អើគទ្រភៈ ប្រសិនបើវិមាននេះនៅឆ្ងាយ មិនជាប់ចង្អៀតចង្អល់ណាស់ណាទេ, គួរតែតថាគតនៅឈប់សម្រាកក្នុងរាត្រីយប់នេះ" ។

យក្សនាយទ្វារទូលសូមអង្វរទៀតថា "បពិត្រព្រះលោកនាថដ៏-ចំរើន ខ្ញុំព្រះអង្គនេះឥតសល់ក្រអឺនឹងព្រះអង្គទេ! តែក្រែងអាឡវិកយក្សគេនឹងធ្វើទុក្ខទោសខ្ញុំព្រះអង្គ រហូតដល់ផ្តាច់ផ្តិលជីវិតក៏មិនដឹង; ព្រោះខ្ញុំព្រះអង្គមិនទាន់បានសូមអនុញ្ញាតគេជាមុន; បើដូច្នោះ ចាំខ្ញុំព្រះអង្គនឹងទៅប្រាប់អាឡវិកយក្សនោះ ឥឡូវនេះសិន" ។

ព្រះអង្គទ្រង់ត្រាស់ថា "អើតទ្រភៈ ចូរអ្នកទៅប្រាប់អាឡវិកយក្សដោយស្រួលបួលចុះ" ។ យក្សនាយទ្វារទទួលព្រះពុទ្ធដីកាហើយក្រាបបង្គំទូលវិញថា "បពិត្រព្រះទសពលដ៏ចំរើន, សូមព្រះអង្គទ្រង់ផ្ទាប់ចុះ" រួចក៏ថ្វាយបង្គំលាព្រះសម្ពុទ្ធហោះសំដៅទៅកាន់ព្រៃហិមវន្ត ក្នុងមួយរំពេចនោះឯង" ។

ឯទ្វារវិមានរបស់យក្សក៏របើកឯង ថ្វាយព្រះសម្ពុទ្ធជាម្ចាស់មួយរំពេចនោះដែរ; ទើបព្រះអង្គស្តេចចូលទៅខាងក្នុងវិមាននោះ ហើយទ្រង់គង់លើបល្ល័ង្កកែវដ៏ជាទិព្វ ត្រង់ល្វែងដែលអាឡវិកយក្សគេសន្មតថា ជាមង្គលហើយសោយនូវសិរីសម្បត្តិតាមនិយម ; លុះទ្រង់គង់ស៊ប់ហើយ ទើបបញ្ចេញរស្មីមានពណ៌ដូចជាមាស ឲ្យភ្លឺរន្ទាលប្រាលល្អៀង ពួកស្រីស្នំរបស់យក្សបានឃើញហើយ ទើបនាំគ្នាមកថ្វាយបង្គំ អង្គុយគាល់ព្រះអង្គ ។ ក៏ទ្រង់សំដែងនូវបកិណ្ណកកថាចំពោះពួកស្រីស្នំទាំងនោះថា

"អ្នកទាំងឡាយ បានបរិច្ចាគទាន, បានរក្សាសីល, បានធ្វើសក្ការបូជាដល់បុគ្គលដែលគួរដល់កិរិយាបូជា ក្នុងកាលមុនច្រើន ទើបអ្នកបានមកសោយសម្បត្តិទិព្វក្នុងកាលឥឡូវនេះ; បើដូច្នោះ អ្នកទាំងឡាយ ត្រូវធ្វើបុញ្ញកិរិយាវត្ថុដូចមុនទៀត, អ្នកទាំងឡាយ កុំប្រណែនឈ្នានីសដល់គ្នាឯងឡើយ" ។

ស្រីស្នំទាំងនោះ លុះបានស្ដាប់មធុរទេសនាដ៏ពីរោះ ទើបនាំគ្នាថ្វាយសព្វសាធុការ ចំពោះព្រះដ៏មានព្រះភាគ ហើយអង្គុយគាល់ព្រះដ៏មានព្រះភាគក្នុងវិមាននោះឯង ។

ឯគទ្រភៈយក្សជានាយទ្វារ ក៏ទៅដល់ព្រៃហិមវន្ត បានជួបនឹងអាឡវកយក្ស ហើយប្រាប់អាឡវកយក្សថា "នែអ្នកដ៏ចំរើន សូមអ្នកជ្រាបចុះ ព្រះដ៏មានព្រះភាគកំពុងគង់នៅក្នុងវិមានរបស់អ្នកឯណោះ" ។ អាឡវកយក្សបានស្ដាប់ហើយ ក៏ឲ្យសញ្ញាដល់គទ្រភយក្សថា "អ្នកត្រូវនៅឲ្យតែស្ងៀមចុះ ចាំយើងទៅហើយនឹងធ្វើទុក្ខទោសដល់សមណៈនោះតាមគួរនឹងការ" ។

ជួនជាគ្រានោះ ពួកសាតាគិរិយក្សព្រមទាំងពួកយក្សជាបរិវារ នាំគ្នាត្រាច់មកតាមអាកាសដោយយានផ្សេងៗ, មានបំណងថានឹងទៅថ្វាយបង្គំព្រះដ៏មានព្រះភាគជាមុនសិន រួចហើយសឹមចូលទៅកាន់ទីយក្សសន្និបាត

ផាខាងក្រោយ; មួយទៀតសោត ក្នុងផ្ទៃអាកាសទាំងអស់ ឥតមានផ្លូវដែលមានទំនងនឹងត្រាច់ទៅសោះ; ព្រោះវិមានដែលឋិតនៅតាមអាកាសសឹងទើសគ្នានឹងគ្នា មានតែផ្លូវទៅកាន់គ្នាពីមួយទៅមួយប៉ុណ្ណោះ, ពុំមានផ្លូវនឹងទៅរហូតបានឡើយ; ឃើញតែវិមានរបស់អាឡវកយក្សដែលប្រតិស្ឋានទុកនៅលើផែនដី, ជាវិមានសុក្កសម្ភ មានកំពែងព័ទ្ធជុំវិញ, មានខ្លោងទ្វារជិតស្និទ្ធល្អ, ប៉ែកខាងលើពាសដោយសំណាញ់ដែកប្រហែលដូចជាគ្របចាប, មានកំពោះ ៣ យោជន៍, ខាងលើវិមាននោះទើបមានផ្លូវសមគួរនឹងទៅបាន; តែពួកសាតាគិរិយក្សបែរជាទៅមិនបានវិញ; ព្រោះព្រះដ៏មានព្រះភាគស្តេចគង់នៅក្នុងវិមាននោះ ។

ក៏ធម្មតាព្រះពុទ្ធគ្រប់ព្រះអង្គ បើស្តេចប្រថាប់នៅត្រង់ប្រទេសណា, ឥតមានសត្វណាមួយ រាប់តាំងពីមនុស្សដរាបដល់ភវគ្គព្រហ្មលោកនាយ ហ៊ានត្រាច់កន្លងលើប្រទេសនោះឡើយ; បានជាពួកសាតាគិរិយក្សឃើញព្រះដ៏មានព្រះភាគហើយ ទើបចុះពីអាកាស គួរនាដូចជាដុំដីធ្លាក់មកកាន់ផែនដី ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ បានស្តាប់ធម៌ទេសនាហើយ ក៏សរសើរគុណព្រះរតនត្រ័យដោយច្រើន ទើបធ្វើប្រទក្សិណាលាទៅកាន់យក្សសមាគមទៅ ។

ឯអាឡវិកយក្ស បានដឹងថាពួកសាតាគិរិយក្ស អង្គុយនៅទីនោះ ក៏បើកឱកាសឲ្យហើយចៀសចេញទៅដែរ ។

ទើបពួកសាតាគិរិយក្ស ប្រាប់អាឡវិកយក្សថា «នែអាឡវិកយក្ស អ្នកពេញចិត្តមនុស្សមានលាភ, ព្រោះព្រះដ៏មានព្រះភាគកំពុងគង់នៅក្នុងវិមានរបស់អ្នក, នែអាឡវិកយក្សដ៏ចំរើន បើអ្នកទៅដល់ហើយត្រូវអ្នកចូលទៅអង្គុយជិតព្រះអង្គចុះ» ។

លំដាប់នោះ អាឡវិកយក្សចូលទៅដល់ហើយ បង្គាប់ឲ្យព្រះអង្គចុះចេញពីវិមាន និងហៅឲ្យចូលមកវិញ ដូចបានពណ៌នារួចមកហើយពីខាងដើម ។

មានពាក្យសួរថា "អាឡវិកយក្សនេះ ពោលពាក្យដូច្នេះ តើព្រោះហេតុអ្វី?" ។

ពាក្យឆ្លើយថា "ព្រោះអាឡវិកយក្ស ទឹងអន់ចិត្តនឹងព្រះអង្គណាស់" ។

ក៏ធម្មតាពាក្យថា "សទ្ធា" សេចក្ដីជឿនេះ ជាពាក្យមិនពីរោះពិសាដល់អ្នកដែលឥតមានសទ្ធា, ដូចពាក្យថា "សីល" ជាពាក្យមិនពីរោះពីសាដល់អ្នកទ្រុស្តសីលដូច្នោះដែរ; ព្រោះហេតុនោះ អាឡវិកយក្ស លុះឮពាក្យសរសើរព្រះពុទ្ធអង្គអំពីពួកយក្សទាំងនោះហើយ ក៏រឹតតែ

ទិនក្រោធខ្ញាចផ្សាយានក្នុងហឫទ័យ ដូចជាដុំអម្បិលដែលគេបង់ចុះក្នុងភ្លើង, ហើយស្រែកសន្ធាប់ថា នរណាហ្ន៎ ព្រះដ៏មានព្រះភាគ ម្តេចក៏ហ៊ានចូលមកកាន់វិមានរបស់យើង ឥតប្រាប់យើងជាមុនសោះ ។

ពួកយក្សទាំងនោះ និយាយតបថា "នែអាឡវកយក្សដ៏ចំរើន អ្នកមិនដឹងទេឬ? ព្រះដ៏មានព្រះភាគជាគ្រូរបស់យើងនេះ' ដើមឡើយស្តេចឋិតនៅក្នុងពិភពតុសិត, ទ្រង់រមិលមើលនូវបញ្ចមហាវិលោកនៈទាំង ៥ (១) ឃើញច្បាស់លាស់ហើយ ទើបស្តេចច្យុតចុះពីភពតុសិតមកកើតក្នុងមនុស្សលោកនេះ, ជាឱរសរបស់ក្សត្រិយ៍ បានគ្រប់គ្រងរាជ-សម្បត្តិសមគួរដល់កាលហើយ, ទ្រង់ចេញបព្វជ្ជាធ្វើទុក្ករកិរិយា រហូតដល់បានត្រាស់ដឹងជាព្រះពុទ្ធ, ទ្រង់សំដែងព្រះធម្មចក្កចំពោះពួកបញ្ច-វគ្គិយភិក្ខុ, អ្នកមិនឃើញអស្ចារ្យនេះទេឬ?" ។

អាឡវកយក្សនោះ សូម្បីឃើញពិតៗក៏តបថាមិនឃើញដែរ ដោយអំណាចសេចក្តីក្រោធ ។ ទើបពួកយក្សទាំងនោះនិយាយទៀតថា "នែអាឡវកយក្ស អ្នកចង់ឃើញក្តី, មិនឃើញក្តី, ក៏មិនប្រយោជន៍អ្វីដែរ, បើអ្នកត្រូវការនឹងធ្វើអ្វីក៏ធ្វើតាមការរបស់អ្នកចុះ; ឯអ្នកនេះ បើនឹងយកមកប្រៀបផ្ទឹមនឹងព្រះដ៏មានព្រះភាគជាគ្រូរបស់យើងហើយ អ្នកនឹងថោកថយជាធំពេកណាស់, ប្រហែលដូចជាកូនគោតូចទើបនឹងកើត ១ ថ្ងៃស្ថិតនៅជិត

---

១ គឺរមិលមើល កាល; ប្រទេស; ទ្វីប, ត្រកូល, មាតា ។

គោឧសភៈដំធំ, ឬដូចកូនកង្កែបតូចស្ថិតនៅជិតដំរីចុះប្រេងដ៏ធំ ឬក៏ដូចចចក
ចាស់ស្ថិតនៅជិតកេសររាជសីហ៍ ផងស្តេចម្រឹគដែលមានខ្លួនធំ, ពុំនោះដូច
កូនក្អែកមានស្លាបជ្រុះអស់ ស្ថិតនៅជិតស្តេចគ្រុឌដែលមានខ្លួនធំប្រមាណ
១ យោជន៍ដូច្នោះដែរ, អ្នកចូលទៅជាប្រញាប់ អ្នកចង់ធ្វើអ្វីក៏ធ្វើចុះតាម
ការរបស់អ្នក» ។ លុះពួកយក្សទាំងនោះនិយាយដូច្នោះហើយ អាឡវក-
យក្សក៏រឹងរឹតតែខឹងក្រោធឡើង ៖ ក្រវីក្រវា ឈរលើថ្មមនោសិលា (១)
ដោយជើងឆ្វេង ស្រែកគម្រាមថា នែអ្នកទាំងឡាយ ចូរមើលចុះ គ្រូ
របស់អ្នកមានអានុភាពធំជាង ឬយើងមានអានុភាពធំជាង; ថាហើយក៏ស្ទុះ
ទៅជាន់លើកំពូលភ្នំកៃលាស ដែលមានកំពស់ ៦០ យោជន៍ ដោយជើង
ខាងស្តាំ; ធំណែកដុំដែក ដែលរបែកចេញអំពីភ្នំ ដូចគេប្រហារដោយ
ញញួរដែក អាឡវកយក្សក៏ឈរនៅលើភ្នំនោះហើយបញ្ចេញសម្រែកថា (២)

---

១ ថ្មដែនមួយឈ្មោះមនោសិលា ។ ២ សម្រែកដែលលាន់ឮរំពងទៅក្នុងជម្ពូទ្វីបយ៉ាង
នេះមាន ៤ យ៉ាង គឺ សំឡេងបុណ្ណកយក្ស ជាសេនាបតីរបស់យក្សដែលទះដៃ ស្រែកថាយើង
ឈ្នះហើយ ៗ ក្នុងវេលាដែលលេងល្បែងជាមួយនឹងស្តេចធនញ្ជយកោរព្យរាជ ១; សំឡេងសក្ក-
ទេវរាជដែលនិម្មិតរូបទេវបុត្រឲ្យនិម្មិតទៅជាសុនខ ហើយស្រែកថាយើងនឹងខាំស៊ីពួកភិក្ខុ, ភិក្ខុនី,
ឧបាសក, ឧបាសិកា ចិត្តបាបជាអធម្មវាទី ក្នុងកាលសាសនាព្រះពុទ្ធកស្សបទៀបរលំចុះ ១;
សំឡេងមហាបុរស កាលយកព្រះជាតិជាកុសរាជពោធិសត្វ មានក្សត្រទាំង ៧ អង្គ
ច្បាំងបណ្តើមព្រះនគរព្រោះនាងបភាវតី ទ្រង់នាំនាងបភាវតីឡើងគង់លើហត្ថីចេញពីព្រះនគរ
ហើយស្រែកថា យើងនេះហើយឈ្មោះសីហស្សរ កុសមហារាជ ១; សំឡេងអាឡវកយក្សដែល
ឈរលើកំពូលភ្នំកៃលាសហើយស្រែកថាយើងឈ្មោះអាឡវកយក្ស ១ (អដ្ឋកថា) ។

«យើងនេះហើយដែលឈ្មោះអាឡវិកយក្ស» ។ សម្រែកក៏លាន់ឮកងរំពង ផ្សាយទៅពេញជម្ពូទ្វីបទាំងមូល ហាក់ដូចជាគេឈរនៅមាត់ទ្វារជម្ពូទ្វីប ហើយស្រែកឡើងដូច្នោះដែរ ។

សព្វគ្រឿងហិមពាន្តដែលមានទំហំ ៣ ពាន់យោជន៍ដល់ម្ល៉ោះ ក៏កង់កម្រើកញាប់ញ័រដោយអានុភាពរបស់យក្ស, ទើបអាឡវិកយក្សបណ្ដាលជាមណ្ឌលខ្យល់ធំ, មានបំណងនឹងឲ្យបក់ប៉ើងព្រះអង្គ, មណ្ឌលខ្យល់នោះតាំងឡើងពីទិសខាងកើតជាដើម ហើយបោកបក់កំពូលភ្នំ ដែលមានធំប្រមាណកន្លះយោជន៍ខ្លះ, ១ យោជន៍ខ្លះ, ២ យោជន៍ខ្លះ ៣ យោជន៍ខ្លះ, បោកទៅលើព្រៃធំតូច ធ្លាយរហូតដល់ក្រវែងឡើង, បោកកំទេចកំទេចរោងដំរី សេះជាដើម, បំប៉ើងក្បឿងប្រក់ហើរសណ្ដែតពាសពេញអាកាស, លុះធ្លាក់មកដល់ជិតព្រះទសពលហើយ ក៏ស្ងប់ឈឹង ពុំអាចបំប៉ើងព្រះអង្គបានឡើយ, សូម្បីតែជាយចីវរ, ក៏មិនរញ្ជួយបន្តិចបន្តួច, ដោយអំណាចសេចក្ដីអធិដ្ឋានរបស់ព្រះអង្គថា « កំហុសកុំគប្បីមានដល់អ្នកណាមួយឡើយ » ។

លំដាប់នោះ អាឡវិកយក្ស បណ្ដាលជាភ្លៀងធំ, បំណងនឹងឲ្យជន់ជោរលិចព្រះអង្គដោយជំនន់ទឹក, ភ្លៀងក៏តាំងឡើងមានគ្រាប់ធំៗ ប៉ុនៗ ចំនួន ១០០ គ្រាប់ខ្លះ, ១០០០ គ្រាប់ខ្លះ, បង្អុរចុះមក, លុះធ្លាក់មកដល់ផែនដី, ក៏បែកខ្ទេចខ្ទីដោយកំឡាំងទឹក, ជំនន់ក៏ហូរជន់ជោរលិចលើ

ព្រៃតូចធំដើមឈើតូចធំ, តែយ៉ាងណាក៏ដោយ ក៏មិនអាចនឹងទទឹកព្រះកាយព្រះអង្គបន្តិចតួច, សូម្បីប៉ុនដំណក់ទឹកសន្សើមបានឡើយ ។

បណ្ដាលជាភ្លៀងផ្កាថ្មមានដុំធំៗ ប៉ុនកំពូលភ្នំ, បាចសាចមកតាមអាកាស, លុះធ្លាក់មកដល់ជិតព្រះទសពលហើយ, ក៏ក្លាយជាកម្រងផ្កាទិព្វគ្រឿងបូជាទៅវិញ ។

បណ្ដាលជាភ្លៀងគ្រឿងប្រហារ គឺអាវុធមុខម្ខាងខ្លះ មុខទាំងសងខាងខ្លះ, ជាដាវលំពែងកូនសរជាដើមខ្លះ បានសាចមកតាមអាកាស; លុះធ្លាក់មកដល់ជិតព្រះទសពលហើយ, ក៏ក្លាយជាផ្កាទិព្វគ្រឿងបូជាទៅវិញ ។

បណ្ដាលជាភ្លៀងរងើកភ្លើង, ក្រហាមរងាលព្រាលឆ្អៅ, ដូចផ្កាបារ ធ្លាក់មកតាមអាកាស, ត្រឡប់ក្លាយជាផ្កាទិព្វគ្រឿងបូជាទៀត ។

បណ្ដាលជាភ្លៀងផេះក្ដៅ, ធ្លាក់មកតាមអាកាស, ក៏ក្លាយជាលំអិតខ្លឹមចន្ទន៍ទៅវិញ ។

បណ្ដាលជាភ្លៀងដីខ្សាច់, ដែលមានគ្រាប់ល្អិត, ធ្លាក់មកតាមអាកាស, ក៏ក្លាយទៅជាផ្កាទិព្វគ្រឿងបូជាទៀត ។

បណ្ដាលជាភ្លៀងភក់កខ្វក់, ធ្លាក់មកតាមអាកាស, ក៏ក្លាយជាគ្រឿងក្រអូបទិព្វគ្រឿងបូជាទៅវិញ ។

បណ្ដាលជាងងឹត, ដូចងងឹតដែលប្រកបដោយអង្គ ៤ (១)ក៏ក្លាយជាភ្លឺដូចរស្មីព្រះអាទិត្យ, ក៏បាត់ងងឹតឲ្យបាត់ទៅវិញ ។

អាឡវកយក្ស, តែងបណ្ដាលជាឫទ្ធិផ្សេងៗរបស់វារៈ ៩ ដងមានខ្យល់ជាដើម, គង់មិនអាចនឹងបណ្ដេញព្រះដ៏មានព្រះភាគឲ្យចុះចេញបាន; ទើបចូលទៅជិតព្រះដ៏មានព្រះភាគជាម្ចាស់, ជាមួយនឹងសេនាមានអង្គ ៤(២) ប្រដូកប្រដៀតគ្នាដោយពួកភូតមានរូបច្រើនសណ្ឋាន, ប្រុងនឹងប្រហារផ្សេងៗពីគ្នា; ពួកភូតទាំងនោះ, ធ្វើការៈ ស្រែកៗស្រែកគម្រាមថា គ្នាយើងចូរចាប់! គ្នាយើងចូរសម្លាប់! ហាក់ដូចជានឹងធ្លាក់មកពីខាងលើព្រះអង្គ; ពុំនោះសោតដូចជារុយភោមពុំឈាម, ដែលហូរចេញមកពីមុខរំពោស្ទើរជល់ម៉ោះ, ក៏គង់មិនអាចនឹងភោមព្រះអង្គបានឡើយ ។

---

១ ដែលថាងងឹតប្រកបដោយអង្គ ៤ នោះ គឺងងឹតក្នុងថ្ងៃទី ១៤ រោច, យប់កាក់កណ្ដាលអធ្រាត្រ, ដងព្រៃណែនណាន់តាន់តាប់កកគុញ ចង្អៀតទៅដោយដើមឈើដ៏ខ្ពស់ស្រោងស្រងាត់នឹងមេឃដូចជាពពក ចុះរត្ន, ពេលភ្លៀងធ្លាក់, ពេលទាំង ៤ នេះជួបប្រទះគ្នាកាលណា ហៅថា "ងងឹតប្រកបដោយអង្គ ៤ " ។ (សុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ សីលក្ខន្ធវគ្គ ភាគ១, ព្រះសាមញ្ញផលសូត្រ, ទំព័រ ២៤៣ បន្ទាត់ទី ៣ និងសមន្តបាសាទិកអដ្ឋកថាវិន័យ ភាគ១, គ្រង់វេរញ្ជកណ្ឌ, ទំព័រ១៩២, បន្ទាត់ទី ៣)ម្យ៉ាងទៀត លោកបានចងជាគាថាសម្រាប់ចាំងាយថា: ចតុរង្គ តមំ នាម កាឡបក្ខចតុទ្ទសី វនសណ្ឌ ឃនោ មេឃ-បដលំ ច,អឌ្ឍរត្តិ ចនុជម្មន្តរស្យាអប់.(អ-អ)។ ២ ពលសេះ, ពលដំរី, ពលរថ, ពលថ្មើរជើង ។

រឿងចម្បាំងរបស់អាឡវកយក្សនេះ វិសេសជាងគ្រាមារាធិរាជ ១ គ្រាន់តែមកដោយពួកពលច្រើនក៏ពិតមែន, តែថយដៃចាលចាញ់ព្រះបរមគ្រូ, ក៏ត្រឡប់វិលថយក្រោយទៅវិញក្នុងមួយរំពេចនោះ, នាគ្រាសម្រេចពោធិកាល ។

ឯពួកពលរបស់អាឡវកយក្សនេះ មិនមែនដូច្នោះទេ, នៅតែធ្វើរឹករឹងផ្ដេសផ្ដាស, មិនព្រមត្រឡប់ថយក្រោយឡើយ រហូតអស់ពាក់កណ្ដាលរាត្រីយប់នោះ ។

កាលបើអាឡវកយក្ស, បំភ័យព្រះដ៏មានព្រះភាគយ៉ាងនេះអស់កន្លះរាត្រី, ហើយមិនអាចនឹងធ្វើព្រះអង្គឲ្យចុះចេញបានដូច្នោះ, ទើបគិតរំពឹងថា បើដូច្នោះមានតែអាត្មាអញហោលអាវុធឈ្នួតក្បាល, ដែលឥតអ្នកណាឈ្នះនោះវិញ ។

សេចក្ដីដំណាលថា អាវុធដ៏ខ្លាំងបំផុតក្នុងលោកមាន ៤ យ៉ាងគឺ វជិរ-វុធរបស់ព្រះឥន្ទ្រ ១, ដំបងដែករបស់ស្ដេចវេស្សវ័ណ ១, ភ្នែករបស់ព្រះយម ១, ឈ្នួតក្បាលរបស់អាឡវកយក្ស ១, សមដូចបាលីគាថានេះថា

សក្កស្ស វជិរាវុធំ វេស្សវណស្ស គទាវុធំ
យមស្ស នយនាវុធំ អាឡវកស្ស ទុស្សាវុធំ ។

ឯអានុភាពនៃអាវុធទាំង ៤ នោះដូច្នេះ ៖

១ - បើព្រះឥន្ទ្រទ្រង់ខ្ទាស់, ហើយប្រហារវជិរាវុធត្រង់កំពូលភ្នំ សិនេរុ, ភ្នំនឹងដាច់ខ្ទាត់ខ្ទាយចេញពីគ្នា មានចម្ងាយ ១ សែន ៦៨ ពាន់ យោជន៍ (១៦៨ ០០០) រាបស្មើនឹងដែនដី ។

២ - ដំបងដែករបស់ស្តេចវេស្សវ័ណ, បើគេវិងបោលទៅហើយ នឹងដាច់ក្បាលពួកយក្ស, ប្រមាណ ១ ពាន់នាក់ធ្លាក់ចុះ ហើយត្រឡប់ វិលមកដល់ដៃដូចដើមវិញ ។

៣ - ព្រះយមបើទ្រង់ខ្ទាល់ហើយ; គ្រាន់តែឆៀងព្រះនេត្រ, ក៏ពួក យក្សកុម្ភណ្ឌប្រមាណ ១ ពាន់នាក់, ដល់នូវសេចក្តីវិនាស ១ រំពេច, ដូចនា ដូចទងស្លោដែលនេះក្នុងអម្បែងក្តៅដូច្នោះ ។

៤ - អាឡវកយក្សឈ្មោះខិងក្រោធហើយ, បើគេវិងឈ្នួតក្បាល ទៅនាអាកាស, ក៏រាំងភ្លៀងអស់រវាង ១២ ឆ្នាំ ។ បើគេវិងបោលទៅលើ ផែនដី, ក៏ក្រុកជាតិលតាជាតិឈើព្យូសារពើ, សូម្បីត្រស ពោនមិនដុះលូតលាស់ ឡើងបានអស់រវាង ១២ ឆ្នាំដែរ ។ បើគេវិងបោលទៅក្នុងមហាសមុទ្រ, ក៏ រីងទឹកអស់ ប្រៀបដូចជាដំណក់ទឹកដែលរីងក្នុងអម្បែងក្តៅដូច្នោះ ។ បើ គេវិងបោលទៅត្រង់ភ្នំ ៗ, ប្រហែលដូចភ្នំសិនេរុ, ក៏បាក់បែកខ្ទាត់ខ្ទាយ ខ្ទេចខ្ទី ។ ទើបអាឡវកយក្សនោះ, គេវិងទុស្សាវុធ (ឈ្នួតក្បាល)

ដែលមានអានុភាពធំដល់ម្លោះពេញកំឡាំង, ហើយស្ទុះទៅចាប់យកមកវិញ ។

ពួកទេវតាទាំង ១ ម៉ឺនលោកធាតុ, ទាំងទេវតាអ្នកចង់ឃើញចម្បាំង, ក៏មកប្រជុំគ្នាច្រើនពេញផ្ទៃអាកាស, ដោយចំណងថា ថ្ងៃនេះព្រះដ៏មានព្រះភាគ, ស្ដេចទ្រង់ទូន្មានអាឡវកយក្ស; យើងទាំងអស់គ្នា, នឹងបានស្ដាប់ធម៌ទេសនាក្នុងទីប្រជុំនោះ ។

លំដាប់នោះ អាឡវកយក្ស, សសៀរចូលទៅជិតព្រះអង្គ, ហើយគ្រវីផងទុស្សាវុធបោលសំដៅព្រះអង្គ, សូរសំឡេងអាវុធនោះលាន់ឮពេញដ៏អាកាស, ដូចសំឡេងរន្ទះឮគួរឲ្យខ្លាច, បញ្ចេញរស្មីភ្លឺប្រាល; លុះធ្លាក់មកជិតព្រះអង្គហើយ, ក៏ត្រឡប់សាបឥតអានុភាព, ប្រហែលដូចសំពត់ជូតព្រះបាទាទៅវិញ, ដើម្បីនឹងបំបាត់នូវមានះរបស់យក្ស ។ ឯអាឡវកយក្ស, លុះឃើញអស្ចារ្យដូច្នោះហើយ, ក៏អស់អំណាចតេជះ, អស់សេចក្ដីស្រវឹង, អស់ពុតកំណាច, ប្រហែលដូចគោបាក់ស្នែង; ឬប្រហែលដូចពស់ដែលគេដកចង្កូម, ទើបនឹកក្នុងចិត្តថា ទុស្សាវុធរបស់អាត្មាអញនេះ, មិនហ៊ានគម្រាមព្រះសមណៈព្រោះហេតុអ្វីហ្ន៎? ប្រហែលជាព្រះសមណៈនេះ លោកប្រកបដោយមេត្តាព្រហ្មវិហារទេដឹង? បើដូច្នោះអញនឹងផ្ចាញ់ផ្ចាលសមណៈនេះដោយមេត្តាវិញ; លុះគិតហើយ

ទើបដើរចូលសំដៅទៅរកព្រះដ៏មានព្រះភាគ, ហើយបង្គាប់ថា "នែសម-
ណៈ អ្នកចូរចុះចេញ" ដូចបានពណ៌នាមកហើយពីខាងក្រោយ ។

នៅវេលានោះ អាឡវកយក្សគម្រាមទៀតថា "នែសមណៈ ព្រោះហេតុអ្វីបានជាលោកហ៊ានចូលមកដល់វិមានរបស់យើង ដែលមិនទាន់បានទទួលអនុញ្ញាត, ហើយអង្គុយកណ្ដាលស្រីស្នំដូចជាម្ចាស់ផ្ទះនេះ, ដូច្នោះ ការបរិភោគប្រើប្រាស់របស់ដែលគេមិនឲ្យក្ដី, ការនៅប្រឡូកប្រឡំដោយស្រីស្នំរបស់គេក្ដី, អំពើនេះពិតសមគួរដល់លោកសោះឡើយ ។ ហេតុនេះ បើលោកស្ថិតនៅក្នុងភេទជាសមណៈ លោកត្រូវតែចុះចេញ" ។

ពួកពលខ្លះពោលពាក្យដូច្នោះ, ខ្លះពោលពាក្យផ្ទុសពីទា ដទៃៗទៀតអនេកប្រការ ។

មានពាក្យសួរថា ព្រោះហេតុអ្វីបានជាអាឡវកយក្ស ប្រើឲ្យព្រះអង្គចុះចេញ ទ្រង់ក៏ចុះចេញ, ហៅឲ្យចូលមក ទ្រង់ក៏ចូលមក, ជាព្រះអង្គចាញ់អំណាចយក្សឬអ្វី ?

ឆ្លើយថា មិនមែនចាញ់ទេ ព្រះអង្គទ្រង់ជ្រាបច្បាស់ថា "អាឡវកយក្សនេះរឹងរូសណាស់, មិនគួរនឹងទូន្មានដោយឧបាយដ៏រឹងរូសតបវិញឡើយ; កាលបើធ្វើយ៉ាងនេះហើយ ហាក់ដូចជាព្រះអង្គធ្វើឲ្យ

អាឡវកយក្សរឹងរឹតតែកាចថែមលើសដើមទៅទៀត, គួរនាំឲ្យសត្វស្លុតខ្លាច ដែលត្រូវដំណក់ទឹកប្រមាត់ចូលតាមច្រមុះដូច្នោះដែរ, ទើបទ្រង់ទូន្មានដោយឧបាយដ៏ទន់វិញ. ទ្រង់ទទួលថាល្អហើយៗ ចុះចេញទៅ ។

លំដាប់នោះ អាឡវកយក្សគិតក្នុងចិត្តថា សមណៈនេះប្រដៅងាយ ទេតើ អាត្មាអញបង្គាប់តែមួយម៉ាត់ថាឲ្យចុះចេញ, លោកក៏ចុះចេញ, មិនសមបើអាត្មាអញគប្រមាថលោកជាមនុស្សព្រួសលបួល ដោយចម្បាំង ឥតហេតុ, អស់ ១ រាត្រីនេះសោះ, យក្សក៏មានចិត្តទន់ចំពោះព្រះអង្គ ។

ទើបគិតទៀតថា មិនដឹងជាលោកចុះចេញទៅដោយអំពើប្រដៅ ងាយ ឬទៅដោយកំហឹង? បើដូច្នោះមានតែអាត្មាអញគិតល្បងទៀត មើល, ក៏ហៅព្រះអង្គឲ្យចូលមកវិញ, ទ្រង់ទទួលថាល្អហើយៗ ត្រឡប់ ចូលមកវិញ, យក្សល្បងមើលតែយ៉ាងនេះ ២ - ៣ ដង ទ្រង់ធ្វើតាម បង្គាប់គ្រប់ៗ វារៈនោះ, ឥតរឹងទទឹងឡើយ ។

សួរថា «ចុះបើប្រសិនជាព្រះអង្គមិនបន្ទន់តាមយក្សៗនឹងធ្វើទោស ព្រះអង្គដល់ត្រឹមណាទៅ?» ។

ឆ្លើយថា មិនអាចនឹងធ្វើទោសដល់ព្រះអង្គត្រឹមណាទេ, តែចិត្ត របស់យក្ស នៅរឹងរឹងរូសមិនគួរជាភាជនៈត្រងរងព្រះសទ្ធម្មទេសនាបាន ឡើយ, ម្យ៉ាងទៀត មានគួរនាំឲ្យមាតា តែងល្អងលោមទារក ដែលកំពុង

យំទាររបស់អ្វីៗ, ឬប៉ុនប៉ងនឹងធ្វើអ្វីៗ ត្រូវតែឲ្យរបស់នោះៗ បណ្ដោយតាមចំណង់នោះៗ ជាសំណូក ដើម្បីឲ្យសុខចិត្តយ៉ាងណាមិញ, ព្រះអង្គទ្រង់ធ្វើយក្សដែលកំពុងយំដោយកិលេស, ទ្រង់លួងលោមដោយទ្រង់ធ្វើតាមបង្គាប់របស់យក្សដូច្នោះ, ពុំនោះសោតគួរនាដូចមេដោះ តែងឲ្យរបស់អ្វីបញ្ឆោតទារក ដែលកំពុងយំមិនព្រមបៅដោះ ឬច្រៀងបំពេលមឲ្យតែសុខចិត្តបៅ យ៉ាងណាមិញ, ព្រះអង្គទ្រង់បញ្ឆោតយក្សលួមឲ្យតែសុខចិត្តបៅទឹកក្សីរគឺលោកុត្តរធម៌ដូច្នោះដែរ ។

ពុំនោះសោតគួរនាដូចបុរសច្រកគ្រឿងបរិភោគជំមានរស ៤ យ៉ាង(១) បំពេញក្នុងសំបកឃ្លោក សម្រាប់ទទួលទានដើម្បីដំរះទោសគឺសេចក្ដីស្រេកឃ្លាន យ៉ាងណាមិញ, ព្រះអង្គបញ្ចូករសគឺលោកុត្តរធម៌ ៤ យ៉ាងក្នុងចិត្តរបស់យក្ស, ដើម្បីដំរះមន្ទិលគឺសេចក្ដីក្រោធក្នុងសន្ដាន, ដោយទ្រង់ចៀសចេញទៅនឹងចូលមកវិញរាបដល់បីដង យ៉ាងដូច្នោះដែរ ។

លំដាប់នោះ អាឡវកយក្ស ញុំាងចិត្តបាបឲ្យកើតឡើងទៀតថា សមណៈនេះប្រដៅងាយមែន, អាត្មាអញបង្គាប់ឲ្យចុះចេញ, លោកក៏ចុះចេញ, បង្គាប់ឲ្យចូលមក, លោកក៏ចូលមកវិញ, តែបើដូច្នោះអាត្មាអញនឹងធ្វើសមណៈនេះឲ្យលំបាកឲ្យអស់ក្រៀយប់នេះ, រួចហើយនឹងចាប់ជើង

---

១ សប្បិ ទឹកដោះថ្លា, ខីរ ទឹកដោះស្រស់; ទធិ ទឹកដោះជូរ; តេល ប្រេង ។

ត្រវៃងបោលទៅត្រើយទន្លេគង្គាខាងនាយ; លុះគិតស្រេចហើយ ទើប បង្គាប់ឲ្យព្រះអង្គចុះចេញទៅក្នុងវារៈជាគំរប់ ៤ ដង ។

ព្រះអង្គទ្រង់ជ្រាបចិត្តរបស់យក្ស ហើយទ្រង់ប្រកែកថា តថាគត មិនចុះចេញទៅ មិនចូលមកវិញទេ ។

លុះព្រះអង្គប្រកែកដូច្នោះ អាឡវកយក្សស្វែងរកហេតុដ៏ជំនាញ ជាន់ពីមុនៗ, ទើបកំណត់ក្នុងចិត្តថានឹងសួរប្រស្នា,ក៏នឹកថា ការសួរប្រស្នា នោះ, នឹងនាំប្រយោជន៍មកថាងាយដល់ព្រះអង្គណាស់, ត្រឡប់ជាមិនសួរ វិញ ។

ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា នែអាឡវកយក្ស អ្នកគិតធ្វើតថា- គតឲ្យលំបាករហូតអស់រាត្រីយប់នេះ, គិតនឹងចាប់ជើងត្រវៃងបោលទៅ ត្រើយទន្លេគង្គាខាងនាយ, គិតនឹងសួរប្រស្នាផ្ចាញ់ផ្ចាល់តថាគត; ហេតុ នេះបានជាតថាគតប្រកែកនេះ; បើអ្នកគួរធ្វើអំពើណា, ចូរធ្វើអំពើនោះចុះ តាមត្រូវការ ។

មានពាក្យសួរថា ប្រស្នាដែលអាឡវកយក្សប្រុងនឹងសួរតទៅនេះ តើយក្សបានចេះនឹងមកពីសំណាក់លោក-អ្នកណា?

ឆ្លើយថា "បានចេះនឹងតមកពីមាតាបិតារបស់ខ្លួន" មានសេចក្តីដំ- ណាលថា: មាតាបិតារបស់អាឡវកយក្ស បានចូលទៅគាល់ព្រះសម្ពុទ្ធ

ទ្រង់ព្រះនាម កស្សបៈ, បានរៀនប្រស្នា ៨ បទនេះ ព្រមទាំងពាក្យដោះស្រាយ, ហើយបានបង្រៀនអាឡវិកយក្សតាំងពីនៅតូច; លុះកន្លងយូរទៅ អាឡវិកយក្សក៏ភ្លេចពាក្យដោះស្រាយអស់ទៅ, នៅចាំតែប្រស្នា តាំងពីគ្រានោះមក, ទើបឲ្យគេសរសេរកត់ចុះក្នុងផែនមាសរក្សាទុកក្នុងវិមាន ។

ឯប្រស្នាទាំងនោះ សុទ្ធតែជាពុទ្ធវិស័យទាំងអស់, បានជាព្រះដ៏មានព្រះភាគទ្រង់ជ្រាបប្រស្នានោះហើយ, ទ្រង់ឆែកក្នុងព្រះហឫទ័យថា សេចក្ដីអន្តរាយចាកលាភ ដែលឃ្លាតហើយក្ដី, អន្តរាយជីវិតក្ដី, គ្រឿងបរិហារឃាត់បញ្ចាសព្វញ្ញុតញ្ញាណ ឬហាមឃាត់ស្មើចមួយ ១ ព្យាមជាប្រមាណក្ដី, របស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ, ឥតមានអ្នកដទៃធ្វើឲ្យវិនាសបានឡើយ; ព្រោះហេតុនោះទើបទ្រង់សំដែងនូវពុទ្ធានុភាព ដែលជាអសាធារណៈក្នុងលោក ហើយទ្រង់ត្រាស់នឹងអាឡវិកយក្សនោះថា "ម្នាលអាវុសោ តថាគតមិនឃើញមានបុគ្គលណាមួយក្នុងលោក ព្រមទាំងទេវលោក មកធ្វើឲ្យអន្តរាយពុទ្ធានុភាពបានឡើយ"; លុះទ្រង់ត្រាស់យ៉ាងនេះហើយ ទ្រង់ឃាត់ហាមចិត្តដ៏លបៀតបៀនរបស់យក្ស, ទ្រង់ធ្វើឧស្សាហៈ ដែលបម្រុងនឹងសួរប្រស្នា ឲ្យកើតឡើងពេញកម្លាំង ហើយទ្រង់ត្រាស់ថា "ម្នាលអាវុសោ បើអ្នកចង់សួរអ្វីក៏សួរចុះ, ការដោះស្រាយប្រស្នានោះជាភារៈរបស់តថាគត" ។

លុះព្រះអង្គមានព្រះភាគទ្រង់ប្រទានឱកាសយ៉ាងនេះហើយ ទើប
អាឡវកយក្សពោលពាក្យជាគាថាសួរថា:

កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹសុ សុចិណ្ណំ សុខមាវហាតិ
កឹសុ ហវេ សាទុតរំ រសានំ
កថំ ជីវី ជីវិតមាហុ សេដ្ឋំ ។

«អ្វីជាទ្រព្យដ៏ប្រសើរបំផុតរបស់បុរសស្ត្រីក្នុងលោកនេះ? អ្វី
ដែលគេប្រព្រឹត្តល្អហើយ នាំនូវសេចក្ដីសុខមកឲ្យ? អ្វីជា
ដែលមានរសឆ្ងាញ់ជាងរសនានា? អ្នកប្រាជ្ញទាំងឡាយ
ពោលហៅ បុគ្គលដែលរស់នៅយ៉ាងណា, ថាជាអ្នករស់នៅ
ប្រសើរបំផុត? ។

ព្រះបរមគ្រូទ្រង់ត្រាស់តបថា:

សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាទុតរំ រសានំ
បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ ។

«សទ្ធាជាទ្រព្យដ៏ប្រសើរបំផុតរបស់បុរសក្នុងលោកនេះ សុចរិតធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំនូវសេចក្ដី ~~សុខមកឲ្យ ពាក្យសត្យរមែងជាគ្រឿងឆ្ងាញ់ពិសាជាងរសទាំងឡាយ~~ អ្នកប្រាជ្ញហៅបុគ្គលដែលរស់នៅដោយប្រាជ្ញា ថាជាអ្នករស់នៅប្រសើរបំផុត ។

ហេតុអ្វីបានជាថាសទ្ធាជាទ្រព្យដ៏ប្រសើរបំផុត របស់បុរសក្នុងលោកនេះ ។

ព្រោះថា សទ្ធាកាលបើមានហើយ អាចនឹងញ៉ាំងទ្រព្យជាសាមញ្ញ មានកែវកង, ខ្សែរស្វើយ, ពិទូរ្យស្ផ័រកាញ្ចន៍, ប្រាក់មាសនឹងខ្ញុំកំដរប្រុសស្រី សត្វពាហនៈជាដើមក៏កើតឡើងបាន, ឯទ្រព្យជាសាមញ្ញទាំងនេះ មិនអាចនឹងញ៉ាំងទ្រព្យគឺសទ្ធាឲ្យកើតឡើងបានឡើយ, សទ្ធាជាទ្រព្យមានឧបការៈទាំងផ្លូវលោកនឹងផ្លូវធម៌, ចំណែកខាងផ្លូវលោក ដូចយ៉ាងជឿជ្រះតាមពាក្យប្រៀនប្រដៅរបស់លោកអ្នកដែលបង្គាប់បញ្ជាហើយនោះ ក៏ជាហេតុបណ្ដាលឲ្យកើតទ្រព្យដ៏ប្រសើរ គឺលាភ យស សរសើរនឹងសេចក្ដីសុខឲ្យឃើញទាន់ចាន់, ចំណែកខាងផ្លូវធម៌វិញ ក៏តែងសទ្ធានេះនាំឲ្យបំពេញធម៌ផងៗពិតៗ ហើយក៏នឹងបានសេចក្ដីសុខតាមសមគួរ, ព្រោះហេតុ

នោះឯងបានជាលោកពោលថា សទ្ធាឈ្មោះថាជាទ្រព្យដ៏ប្រសើរបំផុតរបស់បុរស ( ស្ត្រី ) ក្នុងលោកនេះ ។

មួយយ៉ាងទៀតថា សទ្ធា ទុតិយា បុរិសស្ស ហោតិ ។

សទ្ធាជាសំឡាញ់ទី ២ របស់បុរស ( ស្ត្រី ) ។

សទ្ធាប្រែដូចម្ដេច? បានសេចក្ដីយ៉ាងណា? សទ្ធា ប្រែថា សេចក្ដីជឿ គឺជឿចំពោះរបស់ដែលគួរជឿ, ជាឈ្មោះរបស់សោភណចេតសិក តែងប្រព្រឹត្តទៅក្នុងអារម្មណ៍ច្រើនប្រការ; ព្រោះហេតុដូច្នោះ សេចក្ដីជឿក្នុងរបស់ដែលមិនគួរជឿនឹងបានឈ្មោះថា «សទ្ធា» ក៏ទេ; លុះតែជឿចំពោះរបស់ដែលគួរជឿមែនៗពិតៗ ទើបឈ្មោះថា សទ្ធាក្នុងទីនេះ ។

មួយយ៉ាងទៀត សទ្ធាក្នុងទីនេះលោកចែកចេញជា២ប្រការ គឺ កម្ម-ស្សកតាសទ្ធា ១ តថាគតពោធិសទ្ធា ១ ; កម្មស្សកតាសទ្ធា គឺជឿថា សត្វមានកម្ម គឺបុណ្យ, បាប, ល្អ, អាក្រក់, ជារបស់នៃខ្លួនៗ; កម្ម-ស្សកតាសទ្ធានេះ ចែកចេញជា ២ យ៉ាងគឺ កម្ម ១ វិបាក ១ ។

កម្មគឺបុណ្យឬបាប ដែលបានធ្វើទុក, វិបាកគឺផលរបស់កម្មដែលបានសោយ រួមសេចក្ដីថា ការជឿថាសត្វមានកម្មជារបស់ខ្លួនៗដែលបានធ្វើទុកហើយ ក៏នឹងត្រូវបានសោយផលរបស់កម្មនោះៗ ។

តថាគតពោធិសទ្ធា  គឺសេចក្ដីជឿក្នុងពោធិញាណ  ការត្រាស់ដឹងរបស់ព្រះតថាគតជាម្ចាស់  តាមទំនងក្នុងព្រះនាមទាំង ៩ មាន ឥតិបិសោ ជាដើម ។

សទ្ធាមានសេចក្ដីដូចអធិប្បាយមកនេះ  បើមានក្នុងសន្ដានៃបុរសបុគ្គលណា  ក៏ឈ្មោះថាជាសំឡាញ់របស់បុរសបុគ្គលនោះ  បើនិយាយដោយឡែកចំពោះ  គឺបុគ្គលដែលមានសទ្ធា  ក៏ឈ្មោះថាមានខ្លួនជាសំឡាញ់របស់ខ្លួននោះឯង ។

មានបទមួយទៀតថា

សទ្ធា ពន្ធតិ បាថេយ្យំ "សទ្ធារមែងចងទុកនូវស្បៀងគឺកុសល" សទ្ធាកើតមានហើយ ក៏អាចឲ្យបំពេញទាន រក្សាសីល ចំរើនមេត្តាភាវនា ដែលជាចំណែកកុសលសុទ្ធ ហើយក៏បានសោយនូវសម្បត្តិទាំង៣ប្រការ គឺ សម្បត្តិមនុស្ស ១, សម្បត្តិទេវតា ១, សម្បត្តិព្រះនិព្វាន ១; បើសទ្ធាមិនកើតឡើងទេ បុណ្យកុសលដទៃ ៗ ក៏មិនអាចនឹងកើតឡើងបានដែរ; ធម្មតាបុគ្គលអ្នកតាំងចិត្តនឹងចេញដើរទៅកាន់ផ្លូវឆ្ងាយជាច្រើនយោជន៍នោះ សុទ្ធតែត្រូវរៀបចំស្បៀងអាហារសម្រាប់តាមផ្លូវរហូតទាល់តែដល់ស្រុកទេសដែលបំរុងនឹងទៅនោះ យ៉ាងណា? បុគ្គលអ្នកមានសទ្ធា ក៏ត្រូវតែរៀបចំស្បៀងគឺកុសលដែលបំរុងនឹងទៅកាន់បរលោក ដូច្នោះដែរ ។

សមដូចបទសុភាសិត ដែលសម្តេចព្រះវជិតមារ ទ្រង់ត្រាស់ទេសនាទុកមកថា សទ្ធា ពន្ធតិ បាថេយ្យំ ដូច្នេះឯង ។ បទមួយទៀតថា

សទ្ធា សាធុ បតិដ្ឋិតា « សទ្ធាដែលតាំងមាំហើយ អាចនឹងញុំាងប្រយោជន៍ឲ្យសម្រេច » ។

សទ្ធាដែលតាំងមាំនោះ តើតាំងមាំយ៉ាងណា ?

លក្ខណៈរបស់សទ្ធាដែលឲ្យសម្រេចប្រយោជន៍បាននោះយ៉ាងណា?

ត្រង់ពាក្យថា សទ្ធាតាំងមាំ នោះមាន ២ យ៉ាងគឺ តាំងមាំមិនអាចត្រឡប់ប្រែប្រួលបាន, បានដល់អចលសទ្ធា ឬលោកុត្តរសទ្ធា ដូចសទ្ធារបស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម មានព្រះអរហន្តជាទីបំផុតនេះឯង ចាត់ជាសទ្ធាដែលតាំងមាំហើយ ១, សទ្ធាដែលតាំងមាំហើយត្រឡប់ប្រែប្រួលទៅវិញបាននោះ បានដល់ចលសទ្ធា ឬលោកិយសទ្ធា ដូចសទ្ធារបស់បុថុជ្ជននេះឯង មិនចាត់ជាតាំងមាំល្អទេ ១ ។

អធិប្បាយថា សទ្ធារបស់ព្រះអរិយបុគ្គល ដែលចាត់ជាតាំងមាំល្អនោះ ព្រោះលោកបានគប់ប្រសព្វនឹងសន្ទិដ្ឋិកផលដែលពិត គឺបានសម្រេចដល់សោតាបត្តិផលហើយ ទើបបានមានសេចក្តីជឿមាំក្នុងធម៌ដែលនឹងអាចជួយឲ្យបានសម្រេចធម៌ពិសេស ខាងលើៗឡើងតទៅទៀត

មានសកទាគាមិមគ្គរហូតដល់បានសម្រេចព្រះអរហត្តផល មិនត្រឡប់ប្រែប្រួលវិញ; ព្រោះហេតុនោះ បានជាលោកចាត់ថាជាសទ្ធាបានតាំងមាំល្អហើយ ។ ចំណែកខាងសទ្ធារបស់បុថុជ្ជន ដែលមិនចាត់ជាតាំងមាំល្អហើយនោះ ព្រោះនៅមិនទាន់បានភប់ប្រសព្វនឹងសន្ទិដ្ឋិកផលដែលពិតនៅឡើយ គ្រាន់តែជួបប្រទះនឹងហេតុផល ដែលក្បៀបធៀបរបស់វិទូៗនោះវុះប៉ុណ្ណោះឯង បើទុកណាជានឹងបានតាំងមាំខ្លះនោះ ក៏ត្រឹមតែមួយពេលមួយគ្រាមួយប៉ុណ្ណោះ យ៉ាងនេះក៏នៅតែអាចត្រឡប់ប្រែប្រួលវិញបាន; ព្រោះហេតុនោះបានជាលោកមិនចាត់ជាតាំងមាំល្អហើយឡើយ ។

សទ្ធាមានសេចក្ដីពិស្ដារជាអនេកដូចរៀបរាប់មកខ្លះក្នុងទីនេះ សឹងជាប់ទាក់ទងដោយបទសុភាសិតច្រើនអនេក លើសវិស័យនឹងនាំមកសំដែងឲ្យបប់សព្វគ្រប់បាន, ទើបព្រះអដ្ឋកថាចារ្យលោកពោលដោយបំប្រួញជាគាថាធម្មបទថា

សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

"បុគ្គលអ្នកមានសទ្ធាទាំងបរិបូណ៌ដោយសីល តែងសម្បូណ៌ទៅដោយយស, ភោគ, ទ្រព្យ ទោះបីបុគ្គលនោះត្រាច់

ទៅកាន់ប្រទេសណា ៗ ក្នុងប្រទេសនោះ ៗ គង់មានគេរាប់អាន គេបូជាមិនខានឡើយ " ។

សំដែងមកក្នុងប្រស្នាទី ១ អស់សេចក្ដីតែប៉ុណ្ណេះ ។

ក្នុងប្រស្នាទី ២ សេចក្ដីថា

ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយនោះ រមែងនាំនូវសេចក្ដីសុខមកឲ្យ; ក្នុងទីនេះអ្វីជាហេតុ? អ្វីជាផល? ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយជាហេតុ ត្រង់នាំនូវសេចក្ដីសុខមកឲ្យបុគ្គលនោះជាផល ។

ធម្មសព្ទនេះបានដល់អ្វី? ធម្មសព្ទបានដល់បរិយត្តិ របៀបពាក្យដែលត្រូវសិក្សាសូត្ររៀន ១, បដិបត្តិ សេចក្ដីប្រតិបត្តិដែលត្រូវប្រតិបត្តិ ១, បដិវេធ: ការត្រាស់ដឹងដែលត្រូវត្រាស់ដឹង ១ ។

តែធម្មសព្ទក្នុងទីនេះ លោកសំដៅយកកុសលកម្មបថទាំង ១០ ប្រការ គឺ កាយកម្ម ៣, វចីកម្ម ៤, មនោកម្ម ៣ រួមជា ១០ ប្រការ និងទាន, សីល, ភាវនា ជាដើម ដែលលោករាប់ថាជាសុចរិតធម៌ក្នុងទីនេះឯង; សុចរិតធម៌នេះ បើបុគ្គលណាបានប្រព្រឹត្តល្អហើយ រមែងនាំនូវសេចក្ដីសុខទាំង ៣ ស្ថាន គឺ សុខក្នុងមនុស្ស១, សុខក្នុងស្ថានសួគ៌ ១ សុខក្នុងព្រះនិព្វាន ១ មកឲ្យដល់បុគ្គលនោះ ។

ធម្មោ ហវេ រក្ខតិ ធម្មចារី

ធម្មោ សុចិណ្ណោ សុខមាវហាតិ

ឯសានិសំសោ ធម្មេ សុចិណ្ណេ

ន ទុគ្គតឹ គច្ឆតិ ធម្មចារី (១) ។

« សុចរិតធម៌តែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តសុចរិតៈ សុចរិតដែលបុគ្គលសន្សំហើយ រមែងនាំនូវសេចក្ដីសុខមកឲ្យ នេះជាអានិសង្សក្នុងកិរិយាសន្សំសុចរិតធម៌ (នោះ) អ្នកប្រព្រឹត្តសុចរិតធម៌មិនដែលទៅកាន់ទុគ្គតិឡើយ » ។

សំដែងមកក្នុងប្រស្នាទី ២ អស់សេចក្ដីតែប៉ុណ្ណេះ ។

ក្នុងប្រស្នាទី ៣ សេចក្ដីថា

សច្ចំ ហវេ សាធុតរំ រសានំ « ពាក្យសច្ចៈហ្នឹងឯង ជារសឆ្ងាញ់ជាងរសនានា » ។

សច្ចៈ បានសេចក្ដីថាដូចម្ដេច បានដល់អ្វីខ្លះ ?

សច្ចៈ បានសេចក្ដីថា ពាក្យទៀងទាត់, ពាក្យពិតត្រង់, ពាក្យមិនប្រែប្រួល បានដល់ការនិយាយពាក្យពិត, ធ្វើតាមការងារពិត, ពាក្យពិត,

---

១ ច្បាប់ខ្លះថា: សោ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ដូច្នេះក៏មាន ។

ការពោលពិតនេះ ជារសញុំាងប្រយោជន៍ឲ្យសម្រេចជាងរសទាំងឡាយ មានរសជូរប្រៃផ្អែមជាដើម ។

ក៏ឯសច្ចសព្ទនេះ ប្រព្រឹត្តទៅក្នុងអត្ថច្រើនស្ថាន គឺប្រព្រឹត្តទៅក្នុងវាចាសច្ចៈ ដូចក្នុងប្រយោគថា «បុគ្គលគប្បីពោលពាក្យសច្ចៈ, មិនគប្បីខឹងក្រោធ» ដូច្នេះជាដើម១, ក្នុងវិរតិសច្ចៈ ដូចក្នុងប្រយោគថា «សមណៈនិងព្រាហ្មណ៍ តាំងស្ថិតនៅក្នុងពាក្យសច្ចៈ១» , ក្នុងទិដ្ឋិសច្ចៈ ដូចក្នុងប្រយោគថា «ជនទាំងឡាយតែងពោលពាក្យសច្ចៈ ថែងពួក ហេតុនាំញុំាងលោកនូវកុសល ក្នុងគន្លងពាក្យពោលផ្សេងៗ ព្រោះហេតុហ្នឹង, ដូច្នេះជាដើម១; ក្នុងព្រាហ្មណសច្ចៈ ដូចក្នុងប្រយោគថា «ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណសច្ចៈទាំងឡាយនេះមាន៤យ៉ាង» ដូច្នេះជាដើម១, ក្នុងបរមត្ថសច្ចៈ ដូចក្នុងប្រយោគថា «សច្ចៈមានតែ១ ឥតមាន ២ ឡើយ» ដូច្នេះជាដើម១, ដូចក្នុងប្រយោគថា «បណ្ដាសច្ចៈទាំង៤ អ្វីជាកុសល» ដូច្នេះជាដើម១ ។

តែក្នុងទីនេះ លោកលើកបរមត្ថសច្ចៈ និព្វានសច្ចៈ និងវិរតិសច្ចៈ ដោយឡែក លោកមានបំណងនិងអធិប្បាយវចីសច្ចៈ១ ប៉ុណ្ណោះ ។

ន័យដទៃទៀតថា: សច្ចៈ មាន៦ប្រការគឺ វាចាសច្ចៈ ពិតអាស្រ័យសំដី១, សម្មតិសច្ចៈ ពិតអាស្រ័យការសន្មតិ ដូចសន្មតថា «យើង, គេ, សត្វ,

បុគ្គល, ប្រុសស្រីជាដើម ១, ភាវសច្ចៈ ពិតខាងសភាវៈ ដូចសត្វនឹងសម្ផស្សដែលវិនាសប្រែប្រួលទៅតាមធម្មតារបស់ខ្លួន ១, បរមត្ថសច្ចៈ ពិតខាងផ្លូវបរមត្ថ ដូចសំដែងអំពីចិត្ត ចេតសិក, រូប, និព្វាន ១, អរិយសច្ចៈ ពិតរបស់ព្រះអរិយបុគ្គល បានដល់សច្ចៈទាំង ៤ គឺ ទុក្ខសច្ចៈ ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ ១, និព្វានសច្ចៈ ពិតខាងព្រះនិព្វាន ១, សមដូចបទសុភាសិតថា

សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា ។

ប្រែថា "វចីសច្ចៈ ជាវាចាមិនស្លាប់ពិត វចីសច្ចៈនេះជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ តែងសន្សំហើយពីមុនៗ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងស្ថិតនៅក្នុងសច្ចៈធម៌ គឺធម៌ជាប្រយោជន៍ខ្លួនឯង ប្រយោជន៍អ្នកដទៃផង តាមធម្មតាមិនឃ្លៀងឃ្លាតឡើយ" ។

ពាក្យថា វាចាមិនស្លាប់នេះឯង ជាគ្រឿងសំដែងសេចក្តីល្អរបស់ពាក្យសច្ចៈឲ្យច្បាស់លាស់ ជាវាចាធ្វើឲ្យសម្រេចប្រយោជន៍គ្រប់ប្រការ; ទុកណាជាបុគ្គលអ្នកពោលនោះស្លាប់ហើយក្តី វាចារបស់គេនោះក៏មិនចេះស្លាប់ រមែងមានអ្នកលើកដំកើងឲ្យសព្វសាធុការពរ អស់កាលជា

និច្ចជានិរន្តរតទៅ, ដូចយ៉ាងព្រះពុទ្ធសាសនារបស់ព្រះបរមគ្រូជាម្ចាស់
នៃយើងទាំងឡាយនេះ ជាវាចាមិនស្លាប់ពិត ។

សុភាសិតមួយបទទៀតថា

សច្ចវាចេន ឧទកំ បិធាយតិ
វិសំបិ សច្ចេន ហនន្តិ បណ្ឌិតា
សច្ចេន ទេវោ ថនយំ បវស្សតិ
សច្ចេ ឋិតា និព្វុតី បត្ថយន្តិ
យេ កេចិមេ អត្ថិ រសា បថព្យា
សច្ចំ តេសំ សាធុតរំ រសានំ
សច្ចេ ឋិតា សមណព្រាហ្មណា ច
តរន្តិ ជាតិជរាមរណស្ស បារំ ។

ប្រែថា "បុគ្គលតែងទប់ទឹកបាន ដោយពាក្យសច្ចៈ, អ្នកប្រាជ្ញទាំងឡាយ កំចាត់ពិសបាន ដោយពាក្យសច្ចៈ, ភ្លៀងបង្អុរទឹកចុះមកបាន ដោយពាក្យសច្ចៈ, ព្រះអរិយបុគ្គលទាំងឡាយ ស្ថិតនៅក្នុងពាក្យសច្ចៈហើយ តែងប្រាថ្នាយកសម្បត្តិព្រះនិព្វានបាន, រសជាតិអ្វីមួយមាននៅលើផែនដី ដែលគេត្រូវការទំពាស៊ី មានរសផ្អែមនិងរសឆ្ងើមជាដើម រសតី

សច្ចៈនេះ ឆ្ងាញ់វិសេសជាងរសទាំងនោះ, សមណៈនិងព្រាហ្មណ៍ទាំងឡាយ ឋិតនៅក្នុងពាក្យសច្ចៈហើយ តែងឆ្លងនូវជាតិជរាមរណៈបាន » ។

ព្រោះហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា:

សច្ចំ ហវេ សាធុតរំ រសានំ ដូច្នេះឯង ។

សំដែងមកក្នុងប្រស្នាទី ៣ អស់សេចក្ដីតែប៉ុណ្ណេះ ។

## ក្នុងប្រស្នាទី ៤ សេចក្ដីថា

« អ្នកប្រាជ្ញពោលហៅបុគ្គល ដែលរស់នៅដោយប្រាជ្ញាថា រស់នៅប្រសើរបំផុត » ។

ឯបុគ្គលក្នុងលោក ច្រើនត្រូវការដោយអាយុយឺនយូរថាជារបស់ប្រសើរ តែថាកាលបើបានស្ដាប់ពាក្យប្រដៅក្នុងព្រះពុទ្ធសាសនាហើយ ក៏គង់ដឹងច្បាស់ថាជារបស់មិនប្រសើរវិញ, ព្រោះជីវិតប្រព្រឹត្តទៅដោយសេចក្ដីល្ងង់ខ្លៅ ដែលអ្នកប្រាជ្ញទាំងឡាយលោកមិនប្រាថ្នានោះ មិនប្រសើរទេ ។

ធម្មតាបុគ្គលរស់នៅដោយឥតប្រាជ្ញា, សូម្បីមានអាយុយឺនយូររហូតដល់ ១ រយឆ្នាំក្ដី ក៏ឥតមានប្រសើរអ្វីតិចតួច ត្រង់ការដែលគ្រាន់តែ

រស់នៅប៉ុណ្ណោះទេ, បើប្រសិនជារស់នៅដោយប្រាជ្ញាវិញ កុំថាឡើយរស់នៅមានអាយុ ១ រយឆ្នាំ សូម្បីមានអាយុតែត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះគង់ប្រសើរជាង, សមដូចពុទ្ធភាសិតក្នុងសហស្សវគ្គ គម្ពីរធម្មបទថា

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

សេចក្តីថា "បុគ្គលណាមានជីវិតរស់នៅ១រយឆ្នាំក្តី តែជាបុគ្គលអាប់ឥតប្រាជ្ញា ជាអ្នកមិនខ្ជាប់ខ្ជួន (ក្នុងគុណសម្បត្តិណាមួយ) ជីវិតរស់នៅតែ១ថ្ងៃរបស់អ្នកដែលមានប្រាជ្ញាមានសមាធិឈានតាំងនៅក្នុងខ្លួន ជីវិតរបស់អ្នកនោះប្រសើរជាង" ។

មួយវិញទៀត គ្រហស្ថ ដែលជាបុគ្គលខ្វាក់តែម្ខាង ឬទាំងសងខាង ក៏ពិតមែន តែគេអាចជម្រះនូវសេចក្តីប្រតិបត្តិរបស់គ្រហស្ថ គឺក្រោកឡើងធ្វើការងារ ទទួលកាន់យកសរណគមន៍ ចាត់ចែងធ្វើទាននិងសមាទានសីល ៥ ឬឧបោសថសីលជាដើមហើយរស់នៅ ជីវិតរបស់គ្រហស្ថនោះឈ្មោះថា រស់នៅដោយប្រាជ្ញា ។

ខាងបព្វជិតក្តី ជម្រះនូវសេចក្តីប្រតិបត្តិរបស់បព្វជិត គឺធ្វើសីលឲ្យហ្មត់ចត់ ធ្វើចិត្តឲ្យជូរផង់ជាដើមដោយប្រាជ្ញា ជីវិតរបស់បព្វជិតនោះឈ្មោះថារស់នៅដោយប្រាជ្ញា, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់សំដែងថា “ការរស់នៅដោយប្រាជ្ញា ទើបជាការរស់នៅប្រសើរបំផុត” ។

ឯបញ្ញានេះ ជាឈ្មោះសោភណចេតសិក តែងប្រព្រឹត្តទៅក្នុងអត្ថច្រើនប្រការដូចសទ្ធរដែរ, តែក្នុងទីនេះ និងសូមចែកចេញជា ៣ ប្រការ គឺ ចិន្តាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការគិត ១, សុតាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការស្តាប់ ១, ភាវនាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការភាវនា គឺចំរើនឲ្យមាន ឬ អប់រំឲ្យកើតឡើង ១ ។

ប្រាជ្ញាដែលបានពោលមកហើយនោះ ចាត់ជា ២ ប្រភេទទៀតគឺ លោកិយប្បញ្ញា ១, លោកុត្តរប្បញ្ញា ១, ។

លោកិយប្បញ្ញា បើចែកតាមលំដាប់ភូមិមាន ៣ គឺ ប្រាជ្ញាប្រព្រឹត្តទៅក្នុងកាមភូមិ ១, ប្រព្រឹត្តទៅក្នុងរូបភូមិ ១, ប្រព្រឹត្តទៅក្នុងអរូបភូមិ ១ ។

លោកុត្តរប្បញ្ញា បើរាប់តាមប្រាជ្ញារបស់លោកអ្នកសម្រេចធម៌នោះៗ មាន ៩ គឺមគ្គ ៤, ផល ៤, និព្វាន ១ ។

បើបែកតាមជាន់ទាបនិងជាន់ខ្ពស់ ក៏ចាត់ជា ២ ស្ថានទៀត គឺ ប្រាជ្ញាឃើញសេចក្ដីកើត សេចក្ដីរលត់នៃសព្វវត្ថុទាំងពួងដែលជាខាងក្រៅ ចាត់ជាប្រាជ្ញាជាន់ទាប ប្រាជ្ញាឃើញអរិយសច្ចទាំង ៤ ចាត់ជាប្រាជ្ញាជាន់ខ្ពស់ ។

ប្រាជ្ញាអប់រំឲ្យកើតឲ្យចំរើនក្រៃលែងបាន ដោយហេតុច្រើនប្រការ មានការស្ដាប់និងការប្រកបព្យាយាមជាដើម ។ សមនឹងពុទ្ធភាសិតថា សុស្សូសំ លភតេ បញ្ញំ "ស្ដាប់ដោយល្អ រមែងបានប្រាជ្ញា" ។ បទមួយទៀតថា យោគា វេ ជាយតេ ភូរិ "ប្រាជ្ញាតែងកើតព្រោះប្រកបព្យាយាម" ដូច្នេះ ។ បទមួយទៀតថា សុខោ បញ្ញាបដិលាភោ "ការបាននូវប្រាជ្ញា ជាហេតុឲ្យកើតសេចក្ដីសុខ" និងបទថា បញ្ញាយ បរិសុជ្ឈតិ "បុគ្គលរមែងបរិសុទ្ធបានព្រោះប្រាជ្ញា" ។ បទមួយទៀតថា នត្ថិ បញ្ញាសមា អាភា "ពន្លឺអ្វីមួយស្មើដោយពន្លឺប្រាជ្ញាមិនមានឡើយ" ។

ក៏ធម្មតាពន្លឺក្នុងលោកមាន ៣ យ៉ាង គឺ ពន្លឺព្រះអាទិត្យ ១, ពន្លឺព្រះចន្ទ ១, ពន្លឺភ្លើង ១, បើរាប់ប្រាជ្ញាជាពន្លឺមួយទៀត ក៏ត្រូវជាពន្លឺក្នុងលោកមាន ៤ យ៉ាង, តែត្រង់ពន្លឺទី ៤ ផ្សេងគ្នាដោយនិពន្ធគាថាដូច្នេះ

ចត្តារោ លោកេ បជ្ជោតា បញ្ចមេត្ថ ន វិជ្ជតិ

ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា

អថ អគ្គិ ទិវារត្តឹ តត្ថ តត្ថ បភាសតិ

សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា ។

ពន្លឺក្នុងលោកសន្និវាសនេះមានតែ ៤ គត់ មិនដែលមានដល់ ៥ ឡើយ; គឺពន្លឺព្រះអាទិត្យបំភ្លឺបានតែក្នុងពេលថ្ងៃ, ពន្លឺព្រះចន្ទ្របំភ្លឺបានតែក្នុងពេលយប់, ពន្លឺភ្លើងបំភ្លឺបានតែក្នុងទីនោះៗ ទោះបីយប់ថ្ងៃ តាមគួរគឺការ, ឯព្រះសម្មាសម្ពុទ្ធព្រះអង្គជាពន្លឺប្រសើរបំផុតជាងពន្លឺដ៏វិសេស មានដួងព្រះអាទិត្យជាដើម ដែលជាអ្នកបំភ្លឺនោះៗ, ព្រោះថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក្តី ឬប្រាជ្ញានោះក្តី ក៏ជាពាក្យរួមចុះជាមួយគ្នា បែកតែពាក្យដែលពោលថា ព្រះសម្មាសម្ពុទ្ធៈ ជាបុគ្គលាធិដ្ឋានទេសនា, ឯប្រាជ្ញានោះ ជាធម្មាធិដ្ឋានទេសនាប៉ុណ្ណោះ ។

ក៏បណ្តាពន្លឺទាំង ៤ នោះ បើនឹងប្រៀបគ្នាសម្រាប់ឲ្យជាប្រយោជន៍ពិតប្រាកដ ដល់សត្វអ្នកត្រូវការប្រាជ្ញាយកសេចក្តីសុខតែម្យ៉ាងនោះ ក៏ត្រូវលើកប្រាជ្ញាជាប្រយោជន៍ពិតប្រាកដមែន ។

សំដែងមកក្នុងប្រស្នាទី ៤ អស់សេចក្តីតែប៉ុណ្ណេះ ។

កាលបើអាឡវកយក្សបានស្ដាប់ប្រស្នាទាំង ៤ ដែលព្រះដ៏មានព្រះ ភាគទ្រង់វិស្សជ្ជនាយ៉ាងនេះរួចហើយ ក៏មានចិត្តត្រេកអររីករាយ ហើយ សួរប្រស្នា ៤ យ៉ាងដទៃទៀតថា៖

កថំសុ តរតិ ឱឃំ? កថំសុ តរតិ អណ្ណវំ?

កថំសុ ទុក្ខមច្ចេតិ? កថំសុ បរិសុជ្ឈតិ?

“សត្វឆ្លងនូវអន្លង់បានដោយសារអ្វី? សត្វឆ្លងនូវសមុទ្របាន ដោយសារអ្វី? សត្វឆ្លងនូវសេចក្ដីទុក្ខបានដោយសារអ្វី? សត្វបរិសុទ្ធបានដោយសារអ្វី?” ។

ព្រះដ៏មានព្រះភាគទ្រង់ដោះស្រាយដោយព្រះគាថាថា

សទ្ធាយ តរតិ ឱឃំ អប្បមាទេន អណ្ណវំ

វីរិយេន ទុក្ខមច្ចេតិ បញ្ញាយ បរិសុជ្ឈតិ ។

អត្ថរសនៃព្រះពុទ្ធដីកានេះថា “សត្វឆ្លងនូវអន្លង់ទាំង ៤ បាន ដោយសារសទ្ធាចេតសិក, សត្វឆ្លងនូវសមុទ្របាន ដោយសារអប្បមាទធម៌, សត្វឆ្លងនូវសេចក្ដីទុក្ខព្រួយបាន ដោយសារវីរិយចេតសិក សត្វបរិសុទ្ធបាន ដោយសារបញ្ញាចេតសិក” ។

## សេចក្ដីអធិប្បាយ

១- តាមទំនៀមមកថា អ្នកស្រុក អ្នកប្រទេស ដែលគេតែងឆ្លងស្ទឹង, ទន្លេ ឬសមុទ្រជាដើមនោះ, សុទ្ធតែគេត្រូវស្វែងរកនាវាតូចធំ ទើបនឹងអាចឆ្លងស្ទឹង ទន្លេ ឬសមុទ្រជាដើមនោះបាន. បើវៀរលែងរបស់ប៉ុណ្ណោះហើយ ក៏មិនអាចនឹងឆ្លងបានឡើយ, ឯក្នុងទីនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា

សទ្ធាយ តរតិ ឱឃំ "សត្វឆ្លងអន្លង់បាន ដោយសារសទ្ធា" ដូច្នេះវិញ ។

អ្វីហៅថា ឱឃៈ? មានប៉ុន្មានយ៉ាង? សភាពមួយយ៉ាងដែលធ្វើចិត្តរបស់សត្វឲ្យលិចលង់ក្នុងកាមគុណទាំង៥ប្រការ នាំឲ្យភ្លេចទាំងកុសលធម៌ធ្វើសត្វមិនឲ្យឆ្លងចាកសមុទ្រគឺសង្សារបាន, សភាពនេះឯងហៅថា ឱឃៈដូចជាជំនន់ទឹក ព្រោះលិចសន្ដតចិត្តរបស់សត្វគ្រប់រូប, ឯឱឃៈនោះមាន ៤ ប្រការ គឺ កាមោឃៈ ជំនន់គឺកាម១, ភវោឃៈ ជំនន់គឺភព ១, ទិដ្ឋោឃៈ ជំនន់ គឺសេចក្ដីយល់ឃើញ ១, អវិជ្ជោឃៈ ជំនន់គឺអវិជ្ជា ១, ជំនន់ទាំង៤ប្រការនេះ នឹងយកទូកសំពៅជាដើមទៅឆ្លងមិនរួចឡើយ, លុះតែយកសទ្ធាទៅធ្វើជាទូកឬសំពៅ ទើបនឹងអាចឆ្លងបាន, ក៏ឯសទ្ធាក្នុងបទនេះសំដៅយកសទ្ធា ២ ប្រការ គឺ បសាទនលក្ខណាសទ្ធា

សទ្ធាដែលមានសេចក្ដីជ្រះថ្លាជាលក្ខណៈ ១, បក្ខន្ទនលក្ខណា សទ្ធា សទ្ធាដែលមានកិរិយាស្ទុះទៅជាលក្ខណៈ ១; សទ្ធាទាំង ២ ប្រការនេះហើយដែលសម្រាប់ឆ្លងដំនន់គឺសេចក្ដីយល់ឃើញខុសនោះ ឲ្យបានជាត្រឹមត្រូវឡើងវិញ; ដូច្នេះបានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា សទ្ធាយ តរតិ ឱឃំ «សត្វឆ្លងនូវឱឃៈបានដោយសារសទ្ធា» ។

(សេចក្ដីបំប្រួញថា សត្វឆ្លងទិដ្ឋិឱឃៈ «អន្លង់គឺទិដ្ឋិ» បាន ដោយសារសោតាបត្តិមគ្គ) ។

២ សត្វឆ្លងនូវសមុទ្រសាគរគឺសង្សារវដ្ដបាន ដោយសារសេចក្ដីប្រឹងប្រយ័ត្ន. សមុទ្រគឺសង្សារវដ្ដដែលមានដំនន់គឺភពជាវដ្ដនេះ សត្វមិនអាចនឹងឆ្លងបានងាយៗរួចទេឡើយ; លុះតែសត្វណា ដែលបានសម្រេចជាសោតាបន្នបុគ្គល ដែលប្រកបព្រមដោយសេចក្ដីមិនប្រមាទ ពោលគឺញ៉ាំងផលជាកុសលទាំងឡាយឲ្យចំរើនឡើងរឿយៗ ហើយញ៉ាំងមគ្គទី ២ គឺសកទាគាមិមគ្គឲ្យកើតឡើង ទើបនឹងអាចឆ្លងបាន ព្រោះហេតុដូច្នេះបានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា អប្បមាទេន អណ្ណវំ «សត្វឆ្លងសង្សារវដ្ដបាន ដោយសារសេចក្ដីមិនប្រមាទ» ។

(សេចក្ដីបំប្រួញថា សត្វឆ្លងភវោឃៈ «អន្លង់គឺភព» បាន ដោយសារសកទាគាមិមគ្គ) ។

៣- សត្វឆ្លងនូវសេចក្ដីទុក្ខបាន ដោយសារសេចក្ដីព្យាយាម ប្រឹងប្រែង ដែលជាឈ្មោះវីរិយចេតសិក, ឯវីរិយៈនេះ ជាអញ្ញសមានាចេតសិក ប្រព្រឹត្តទៅបានទាំងក្នុងចំណែកល្អនិងចំណែកអាក្រក់, ក៏ង ក្នុងពុទ្ធភាសិតនេះ សំដៅយកសេចក្ដីព្យាយាមក្នុងចំណែកល្អតែមួយយ៉ាង, ហេតុនោះបានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា វីរិយេន ទុក្ខមច្ចេតិ "សត្វឆ្លងនូវសេចក្ដីទុក្ខបាន ដោយសារសេចក្ដីព្យាយាម" ។

(សេចក្ដីបំប្រួញថា សត្វឆ្លងកាមោឃៈ "អន្លង់កាម" បាន ដោយសារអនាគាមិមគ្គ) ។

៤- សត្វបរិសុទ្ធបាន ដោយសារប្រាជ្ញា; ប្រាជ្ញាក្នុងទីនេះ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ព្រះអនាគាមិបុគ្គលៈ បានញ៉ាំងប្រាជ្ញាដ៏សម្បយុត្តដោយមគ្គជាគំរប់៤ ឲ្យបរិសុទ្ធដោយចំណែកមួយ ដោយញាណដ៏បរិសុទ្ធ ដែលប្រាសចាកកក់កាម ហើយបានលះបង់នូវមន្ទិលដ៏ល្អិតពោលគឺអវិជ្ជា ដែលព្រះអនាគាមិមិនទាន់លះបង់បាននោះ; ព្រោះហេតុនោះបានជាព្រះអង្គទ្រង់ប្រកាសនូវអរហត្តមគ្គផង, នូវអរហត្តផលផង ដែលជាគ្រឿងឆ្លងចាកអវិជ្ជា ដោយបទថា បញ្ញាយ បរិសុជ្ឈតិ "សត្វបរិសុទ្ធបាន ដោយសារប្រាជ្ញា" ។

(សេចក្ដីប្រែថា សត្តជនឆ្លងអវិជ្ជោឃៈ “អន្លង់គឺអវិជ្ជា” បាន ដោយសារអរហត្តមគ្គ) ។

ក្នុងទីបំផុតនៃគាថា ដែលព្រះអង្គទ្រង់សំដែងដោយកំពូលនៃព្រះ អរហត្តនេះ អាឡវកយក្សបានសម្រេចសោតាបត្តិផល ហេតុដូច្នេះបាន ជាយក្សនោះ ចាប់យកបទបញ្ញាត្រង់ដែលព្រះអង្គទ្រង់សំដែងថា “សត្វ បរិសុទ្ធបានដោយសារប្រាជ្ញា” នោះ យកមកបន្តគ្នាដោយប្រាជ្ញារបស់ ខ្លួន ហើយទើបសួរប្រស្នាដែលលាយឡំទៅដោយលោកុត្តរៈ ដោយបទព្រះ គាថានេះទៀតថា

កថំសុ លភតេ បញ្ញំ? កថំសុ វិន្ទតេ ធនំ?
កថំសុ កិត្តឹ បប្បោតិ? កថំ មិត្តានិ គន្ថតិ?
អស្មា លោកា បរំ លោកំ កថំ បេច្ច ន សោចតិ?

សេចក្ដីក្នុងប្រស្នានេះថា បុគ្គលបានប្រាជ្ញាដោយសារអ្វី? បានទ្រព្យដោយសារអ្វី? ដល់នូវសេចក្ដីសរសើរដោយសារ អ្វី? ចងពួកមិត្តបានដោយសារអ្វី? បុគ្គលទៅពីលោកនេះ ទៅកាន់លោកខាងមុខ មិនបានសោយសោកក្នុងលោកខាង មុខដោយសារអ្វី? ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបដោយបទព្រះគាថានេះថា

សទ្ទហានោ អរហតំ ធម្មំ និព្វានបត្តិយា
សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ
បតិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ
សច្ចេន កិត្តឹ បប្បោតិ ទទំ មិត្តានិ គន្ថតិ
យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ
ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

អត្ថសេចក្តីប្រែថា "បុគ្គលដែលជាអ្នកប្រាជ្ញ មិនមានសេចក្តីប្រមាទ កាលបើបានជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីដល់នូវព្រះនិព្វាន ហើយបានស្តាប់ដោយប្រពៃ រមែងបាននូវប្រាជ្ញា ១, បុគ្គលធ្វើការងារដ៏សមគួរ មានធុរៈ (មិនទម្លាក់ចោល) មានសេចក្តីរវៀសរវៃ រមែងបាននូវទ្រព្យ ១, បុគ្គលបានដល់នូវសេចក្តីសរសើរ ដោយពាក្យពិត ១, បុគ្គលអ្នកឲ្យទាន រមែងចងនូវមិត្តបាន ១, បុគ្គលដែល[illegible] ប្រការទាំង ៤

ប្រការ គឺ សច្ចៈ ( ពាក្យពិត ) ១, ទមៈ (ការទូន្មាន) ១, ធិតិ (សេចក្ដីអត់ធន់) ១, ចាគៈ (ការបរិច្ចាគ) ១, បុគ្គលនោះ រមែងមិនបានសោយសោកក្នុងលោកខាងមុខទៀយ ៗ

បើដូច្នោះ ចូរអ្នកសួរពួកសមណៈឬព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះ វិសេសជាង "សច្ចៈ, ទមៈ, ចាគៈ, ខន្តិទៅទៀត" ៗ

## សេចក្ដីអធិប្បាយ

១– ព្រះអរហន្តគឺព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធនិងពុទ្ធសាវកទាំងឡាយ ដែលលោកបានសម្រេចដល់សម្បត្តិព្រះនិព្វាន ក៏ដោយសារគុណជា ចំណែកខាងដើម គឺបានបំពេញធម៌មានពោធិបក្ខិយធម៌ជាដើម, កាលបើ បុគ្គលបានជឿនូវធម៌របស់ព្រះអរហន្តនោះហើយ រមែងបាននូវលោកិយ បញ្ញានិងលោកុត្តរបញ្ញា ដែលជាគុណឲ្យដល់នូវព្រះនិព្វាន, ក៏ការដែល បាននូវព្រះនិព្វាននោះ មិនមែនបានដោយសារសទ្ធាតែមួយយ៉ាងទេ ព្រោះថា បុគ្គលដែលមានសទ្ធាកើតក្នុងសន្ដានហើយ រមែងចូលទៅរក, កាលបើចូលទៅរកហើយ រមែងចូលទៅអង្គុយជិត, កាលបើចូលទៅ អង្គុយជិតហើយ រមែងផ្ទៀងនូវសោតប្រសាទ, លុះផ្ទៀងនូវសោត ប្រសាទហើយ រមែងបានស្ដាប់នូវធម៌ដែលជាហេតុឲ្យកើតបញ្ញា ទាំង

មិនមានសេចក្តីប្រមាទ ចេះពិចារណានូវបទសុភាសិតនិងទុព្ភាសិត កាល
បើបានស្តាប់ដោយប្រពៃហើយ ក៏តែងបាននូវបញ្ញា ដោយហេតុដែល
បានស្តាប់នោះ មិនមែនបាននូវបញ្ញាដោយហេតុដទៃឡើយ ; លុះបើ
ពិចារណាហើយធ្វើវត្តប្រតិបត្តិ តាមសមគួរដល់ការបាននូវបញ្ញា តាម
កំលាំងសទ្ធា តែងបានស្តាប់នូវឧបាយដែលបាននូវបញ្ញា ដោយការ
ស្តាប់ដោយគោរព គ្រងវង់ដោយការមិនប្រមាទ កាន់យកមិនភ្លាត់មិន
ភ្លេចមិនខ្វះ, ហើយធ្វើបទដែលស្តាប់នោះឲ្យពិស្តារទៅបាន ព្រោះបាន
ស្តាប់ដោយគោរព ទាំងចេះពិចារណាទៅតាម ៗ ព្រោះហេតុនេះ
បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា សុស្សូសំ លភតេ បញ្ញំ
ៗល ៗ អប្បមត្តោ វិចក្ខណោ សុ.ខុ. ៗ

២ - បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ បុគ្គលធ្វើ
ការងារដ៏សមគួរ មានធុរៈមិនទំលាក់ចោល មិនធ្វើប្រយោជន៍ឲ្យកាលឲ្យ
វិនាស តែងធ្វើនូវឧបាយដែលសមគួរដល់ការបាននូវលោកិយទ្រព្យនិង
លោកុត្តរទ្រព្យ ហៅថា បដិរូបការី, ធ្វើព្យាយាមមាំក្នុងចិត្តមិនទំលាក់ធុរៈ
ចោល ហៅថា ធុរវា, បុគ្គលអ្នកមិនសំគាល់ថាក្តៅថាត្រជាក់ ឬហែល
ឃ្លានស្រេកហើយប្រកបការងារ ដោយកំលាំងកាយពេញលេញ ដោយ
ការខំស្វាហាប់មានព្យាយាមមិនបន្ធូរបន្ថយ ហៅថា ឧដ្ឋាតា, បុគ្គលដែល

ប្រកបដោយអង្គទាំង ៣ នេះ រមែងបាននូវលោកិយទ្រព្យ" ដូចជាចុល្លកន្តេវាសិកសេដ្ឋី ដែលប្រកបព្យាយាមក្នុងការជួញតាំងពីដើមទុន ពីត្រឹមខ្មូកណ្តុរ ១ ជាដើម ដរាបដល់បានសម្បត្តិ ៤ សែនកហាបណៈដោយឆាប់រហ័ស នឹងបាននូវលោកុត្តរទ្រព្យ ដូចជាមហាល្លកមហាតិស្សត្ថេរ ដែលជាព្រះអរហន្តនោះ ៕

ដំណើរសេចក្តីថា ព្រះតិស្សត្ថេរនោះ លោកមានបំណងថា អាត្មាអញនឹងសម្រេចដោយឥរិយាបថតែ ៣ គឺ ដើរ, ឈរ, អង្គុយ ហើយលោកក៏ធ្វើវត្តតាមបំណងនោះ; លុះមានថីនមិទ្ធៈមកគ្របសង្កត់វេលាណា លោកក៏ជ្រលក់បាច់ចំបើងឲ្យទទឹក ហើយយកមកទទូរលើសីសៈរបស់លោក ដូចជាជូតក្បាល រួចចុះទៅត្រាំទឹកមានជម្រៅប្រមាណត្រឹមក ដើម្បីបណ្តេញបំបាត់នូវថីនមិទ្ធៈនោះ លោកប្រព្រឹត្តធ្វើតែយ៉ាងនេះរវាង ១០ ឆ្នាំ ក៏បានសម្រេចព្រះអរហត្តផល ជាព្រះអរហន្តមួយអង្គ, ព្រោះហេតុនោះបានជា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ" ម្ភេះ ៕

៣ - សច្ចេន កិត្តឹ បប្បោតិ «ដល់នូវសេចក្តីសរសើរដោយពាក្យពិត» កិត្តិ សេចក្តីសរសើរគឺឈ្មោះ ឬឈ្មោះសំឡេង ដែលគេអាចនឹងទទួលបាន ដោយសារពាក្យពិត គឺសំដីដែលនិយាយ

ទៀងទាត់និយាយត្រង់ ដូចព្រះពុទ្ធដ៏ការព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ឬព្រះបច្ចេកពុទ្ធ អរិយសាវក សំដីទាំងអស់នេះរាប់ថាជាសំដីពិត ព្រោះជាសំដីមិនឡេះឡោះ ដូចមានបទថា: "សច្ចំវទេ ភាសតិ នោ អលិកំ" "បុគ្គលរមែងពោលពាក្យពិតតែមួយយ៉ាង មិនត្រូវពោលពាក្យឡេះឡោះឡើយ" ។ ព្រោះហេតុនោះបានជាព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាដើម សូម្បីទ្រង់និព្វានបាត់ទៅហើយ អស់កាលជាយូរអង្វែង, ក៏គង់មានអ្នកកាន់សាសនា គេនៅរាប់អានលើកសួយសរសើរថាជាពាក្យមានខ្លឹមសារ៉ៗ អាចឲ្យសម្រេចប្រយោជន៍ដរាបមកដល់កាលសព្វថ្ងៃនេះ, ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "សច្ចេន... កិត្តឹ បប្បោតិ" ដូច្នេះ ។ ៕

៤- ទទំ មិត្តានិ គន្ថតិ "ការឲ្យទាន រមែងចងពួកមិត្រទុកបាន" ក៏ពាក្យថា មិត្រ ក្នុងទីនេះ កុំគប្បីចូលចិត្តថាចំពោះយកតែមនុស្សដែលហៅថាសំឡាញ់នោះឡើយ គឺសំដៅយកទូទៅ តាំងពីមនុស្សនៅក្នុងបន្ទុកជាមួយគ្នាជាដើមទៅ សមនឹងពាក្យថា "មាតា មិត្តំ សកេ ឃរេ" "មាតាជាមិត្រក្នុងផ្ទះរបស់ខ្លួន" ភរិយា បរមា សខា ភរិយាជាមិត្រយ៉ាងស្និទ្ធ, បានជាព្រះសាស្តាទ្រង់ត្រាស់ប្រៀនប្រដៅឲ្យមាតាបិតានឹងបុត្រ អាចារ្យនឹងសិស្ស ស្វាមីនឹង

កិរិយាស្រឡាញ់រាប់អានគ្នា ; ម្ចាស់និងបាវព្រាវ គ្រហស្ថនិងបព្វជិត ត្រូវយកចិត្តទាក់ទងគ្នាដោយទំនងនោះៗ ។ ដូចមានសេចក្ដីពិស្ដារក្នុងសិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គឯណោះ ។

ត្រង់ពាក្យថា ឲ្យទាន នោះ មិនមែនត្រាន់តែឲ្យរបស់ប៉ុណ្ណោះទេ ទាំងពោលពាក្យពីរោះក្តី ធ្វើអំពើឲ្យជាប្រយោជន៍ក្តី ទុកដាក់ខ្លួនប្រាណស្មើមិនធ្វើឫកក្តី សង្គហវត្ថុទាំង ៤ ប្រការនេះ ជាចំណងមិត្រស្រឡាញ់បាន ហើយជាសាធារណៈទូទៅទាំងគ្រហស្ថនិងបព្វជិត ក៏គួរប្រតិបត្តិបានទាំងអស់គ្នា, សមដូចបទពុទ្ធភាសិតក្នុងធម្មបទ ១ កន្លែងទៀតថា

"អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ" ។

សេចក្ដីថា បុគ្គលអ្នកឈ្នះក្រោធ ដោយការមិនក្រោធតប, ឈ្នះអសប្បុរស ដោយចិត្តសប្បុរស, ឈ្នះមនុស្សកំណាញ់ ដោយការឲ្យទាន, ឈ្នះជនអ្នកពោលពាក្យឡេះឡោះ ដោយពោលពាក្យទៀងទាត់ៗ ។

ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ទទំ មិត្តានិ គន្ថតិ" ដូច្នេះ ។

៤- យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ទមោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ។

« បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ យ៉ាងនេះគឺ សច្ចៈ (ពាក្យពិត) ១, ទមៈ (ការទូន្មាន) ១, ធិតិ (សេចក្ដីអត់ធន់) ១, ចាគៈ (ការបរិច្ចាគ) ១, រមែងមិនបានសោយសោកក្នុងលោកខាងមុខដោយពិត » ។

លុះព្រះដ៏មានព្រះភាគទ្រង់ដោះប្រស្នា ទាំង ៤ នេះស្រេចហើយ កាលណា ទ្រង់តឿនអាឡវកយក្សដោយព្រះពុទ្ធដីកាថា

ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

« បើដូច្នោះ ចូរអ្នកសួរពួកសមណៈព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះវិសេសជាងសច្ចៈ ទមៈ ចាគៈ ខន្តិទៅទៀត » ។

កាលបើព្រះលោកុត្តមាចារ្យជាម្ចាស់ ទ្រង់ដាស់តឿនដូច្នេះហើយ អាឡវកយក្សក៏ត្រឡប់សូត្រព្រះគាថានេះថ្វាយសព្វសាធុការពរតទៅទៀតថា

កថំ នុ ទានិ បុច្ឆេយ្យំ បុថូ សមណព្រាហ្មណេ
យោហំ អជ្ជ បជានាមិ យោ អត្ថោ សម្បរាយិកោ
អត្ថាយ វត មេ ពុទ្ធោ វាសាយាឡវិមាគមា
យោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ
សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ
នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

"ក្នុងវេលានេះ ខ្ញុំនឹងសួរពួកសមណព្រាហ្មណ៍ច្រើនគ្នាដើម្បីអ្វី? ព្រោះខ្ញុំបានដឹងប្រយោជន៍ក្នុងបរលោកក្នុងថ្ងៃនេះដោយសារ ព្រះអង្គស្ដេចមកក្នុងក្រុងអាឡវី ជាប្រយោជន៍ដល់ខ្ញុំព្រះអង្គៗ ទើបតែនឹងដឹងជាក់ក្នុងថ្ងៃនេះថា៖ ទានដែលបុគ្គលឲ្យដល់បុគ្គលណា ទើបមានផលច្រើន, លុះខ្ញុំចេញពីស្រុកមួយទៅកាន់ស្រុកមួយ ចេញពីបុរីមួយទៅកាន់បុរីមួយ នឹងនមស្សការនូវព្រះសម្ពុទ្ធផង ធម្មតាស់នោះជាធម៌; ព្រះធម៌ដ៏ប្រសើរផង នឹងព្រះសង្ឃផង ចាប់ដើមអំពីថ្ងៃនេះរៀងទៅ" ។

វេលាដែលព្រះសាស្ដាដោះប្រស្នាអាឡវកយក្ស ដោយព្រះគាថានេះចប់ហើយផង, ពេលអរុណរះផង សំឡេងដែលអាឡវកយក្សថ្វាយ

សព្វសាធុការពរជ័យ, ពួករាជបុរសដែលនាំអាឡវកកុមារទៅកាន់ពិភព
យក្សផង ក៏ដល់ព្រមគ្នាខណៈនោះជាមួយគ្នា មិនមុនមិនក្រោយ ។

ឯរាជបុរសទាំងឡាយ កាលបើបានឮសព្ទសាធុការពរដូច្នោះហើយ
រំពឹងគិតថា សំឡេងសព្ទសាធុការពរមានសភាពបែបនេះ លើកលែង
តែព្រះសម្ពុទ្ធបរមគ្រូចេញ មិនមានផ្សាយដល់ពួកជនដទៃទេ, ឱ!! ទំនង
ជាព្រះដ៏មានព្រះភាគជាម្ចាស់ ស្ដេចយាងមកក្នុងទីនេះទេដឹង? ក៏ក្រឡេក
មើលទៅឃើញព្រះរស្មី ដែលផ្សាយចេញពីព្រះសរីរៈព្រះដ៏មានព្រះភាគ
ហើយក៏មិនឈររនៅខាងក្រៅម្លប់ឈើដូចពីកាលមុនឡើយ ក៏នាំគ្នាចូល
ទៅខាងក្នុង ដោយឥតមានរង្កៀសទើសអ្វី; លុះបានឃើញព្រះដ៏មាន
ព្រះភាគកំពុងគង់នៅក្នុងលំនៅរបស់យក្ស ឯយក្សកំពុងតែអង្គុយផ្គង
ប្រណម្យអញ្ជលី, ទើបនិយាយទៅនឹងយក្សថា នែមហាយក្ស នេះព្រះ
រាជកុមារ ដែលពួកយើងនាំយកមកបូជាចំពោះអ្នក, ចូរអ្នកខំបរិភោគ
ព្រះរាជកុមារនេះចុះ ឬចង់ធ្វើយ៉ាងណាៗក៏តាមចិត្តអ្នកចុះ" ឯយក្សនោះ
ហេតុតែខ្លួនជាអ្នកបានសម្រេចដល់ព្រះសោតាបន្នបុគ្គលហើយ ក៏មាន
សេចក្ដីអៀនខ្មាស ហើយទទួលនឹងពាក្យនិយាយយ៉ាងនោះ ក្នុងទីចំពោះព្រះ
ភក្ត្រព្រះដ៏មានបុណ្យ ក៏រឹងរឹតតែអៀនខ្មាសថែមឡើង; លំដាប់នោះ
យក្សទទួលយកព្រះរាជកុមារនោះដោយដៃទាំង ២ នាំចូលទៅថ្វាយព្រះ

ដ៏មានបុណ្យ ហើយក្រាបបង្គំទូលថា :- បពិត្រព្រះអង្គដ៏ចំរើន នេះព្រះរាជកុមារ ដែលគេនាំយកមកឲ្យខ្ញុំព្រះអង្គៗសូមថ្វាយព្រះរាជកុមារនេះចំពោះព្រះបរមគ្រូ ដើម្បីអនុគ្រោះនូវសេចក្តីចំរើន, បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គធ្វើនូវសេចក្តីអនុគ្រោះ ទទួលនូវព្រះរាជកុមារនេះ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ព្រះរាជកុមារនេះផងចុះ រួចហើយអាឡវកយក្សក៏សូត្រនូវព្រះគាថានេះថា

ឥមំ កុមារំ សតបុញ្ញលក្ខណំ
សព្វង្គុបេតំ បរិបុណ្ណព្យញ្ជនំ
ឧទគ្គចិត្តោ សុមនោ ទទាមិ តេ
បដិគ្គហ លោកហិតាយ ចក្ខុម ។

“បពិត្រព្រះចក្ខុមសម្ពុទ្ធដ៏ចំរើន ខ្ញុំព្រះអង្គមានចិត្តត្រេកអរសោមនស្សរីករាយ ហាក់ដូចជាអណ្តែតត្រសែតខ្ពស់ឡើង ខ្ញុំព្រះអង្គសូមថ្វាយព្រះរាជកុមារ ដែលមានបុញ្ញលក្ខណៈដោយរយគុណ បរិបូណ៌ដោយអវយវៈតូចធំសព្វគ្រប់ពេញលេញទៅដោយព្យញ្ជនៈ ចំពោះព្រះអង្គ សូមព្រះអង្គទ្រង់មេត្តាទទួលយក ដើម្បីសង្គ្រោះដល់សត្វលោក” ។

លុះអាឡវកយក្សក្រាបបង្គំលដូច្នេះហើយ ព្រះអង្គស្ដេចទ្រង់ទទួលយកព្រះរាជកុមារនោះទៅ ។ លុះស្ដេចទ្រង់ទទួលហើយ ទើបទ្រង់សំដែងព្រះគាថា ៣ បាទ ដើម្បីធ្វើមង្គលសួស្ដីដល់យក្សនឹងព្រះរាជកុមារនោះ, ឯយក្សក៏សូមព្រះរាជកុមារនោះជាទីពឹងទីរលឹក ហើយបានសូត្របំពេញព្រះគាថានោះឲ្យពេញគ្រប់បាទអស់វារៈ ៣ ដងដូច្នេះ

ទីឃាយុកោ ហោតុ អយំ កុមារោ
តុវញ្ច យក្ខ សុខិតោ ភវាហិ
អព្យាធិតា លោកហិតាយ តិដ្ឋថ
អយំ កុមារោ សរណំ ឧបេតិ ពុទ្ធំ
ទីឃាយុកោ ហោតុ អយំ កុមារោ
តុវញ្ច យក្ខ សុខិតោ ភវាហិ
អព្យាធិតា លោកហិតាយ តិដ្ឋថ
អយំ កុមារោ សរណំ ឧបេតិ ធម្មំ
ទីឃាយុកោ ហោតុ អយំ កុមារោ
តុវញ្ច យក្ខ សុខិតោ ភវាហិ
អព្យាធិតា លោកហិតាយ តិដ្ឋថ
អយំ កុមារោ សរណំ ឧបេតិ សង្ឃំ ។

សេចក្ដីថា « សូមឲ្យព្រះរាជកុមារនេះមានព្រះជន្មាយុវែង, ម្នាលយក្ស ទាំងអ្នកដ៏ចំរើនសោតទៀត ក៏សូមឲ្យបានសេចក្ដីសុខសប្បាយ កុំបីមានជម្ងឺដម្កាត់ឡើយ ចូរស្ថិតនៅ ដើម្បីសេចក្ដីចំរើនដល់សត្វលោក, ព្រះរាជកុមារនេះបានដល់នូវព្រះពុទ្ធជាទីពឹងហើយ ។ សូមឲ្យព្រះរាជកុមារនេះមានព្រះជន្មាយុវែង, ម្នាលយក្ស ទាំងអ្នកដ៏ចំរើនសោតទៀត ក៏សូមឲ្យបានសេចក្ដីសុខសប្បាយ កុំបីមានជម្ងឺដម្កាត់ឡើយ ចូរស្ថិតនៅដើម្បីសេចក្ដីចំរើនដល់សត្វលោក; ព្រះរាជកុមារនេះបានដល់នូវព្រះធម៌ជាទីពឹងហើយ ។ សូមឲ្យព្រះរាជ-កុមារនេះមានព្រះជន្មាយុវែង, ម្នាលយក្ស ទាំងអ្នកដ៏-ចំរើនសោតទៀត ក៏សូមឲ្យបានសេចក្ដីសុខសប្បាយ កុំបីមានជម្ងឺដម្កាត់ឡើយ ចូរស្ថិតនៅដើម្បីសេចក្ដីចំរើនដល់សត្វលោក, ព្រះរាជកុមារនេះបានដល់នូវព្រះសង្ឃជាទីពឹងហើយ ។

លុះព្រះដ៏មានព្រះភាគ ទ្រង់ព្រះរាជទាន ព្រះរាជកុមារឲ្យទៅពួករាជបុរសហើយ ទ្រង់មានព្រះពុទ្ធដីកាថា « អ្នកទាំងឡាយចូរញុំាងព្រះរាជកុមារនេះឲ្យចំរើន ហើយឲ្យមកតថាគតវិញ ព្រះរាជកុមារនោះ

ក៏បាននាមថា ហត្ថកអាឡវកៈ ដោយហេតុថា ព្រះរាជកុមារនោះ អាឡវកយក្សបានទទួលអំពីដៃពួករាជបុរស ព្រះដ៏មានព្រះភាគទ្រង់ទទួលអំពីដៃយក្ស ឯពួករាជបុរស បានទទួលអំពីព្រះហស្តព្រះដ៏មានព្រះភាគត្រឡប់មកវិញ បណ្តាជនទាំងអម្បាលម៉ាន កាលបើបានឃើញពួករាជបុរស នាំព្រះរាជកុមារត្រឡប់មកវិញដូច្នោះ ក៏គិតគ្នាថា "យក្សប្រហែលជាមិនត្រូវការនឹងស៊ីព្រះរាជកុមារ ព្រោះក្មេងពេកទេដឹង? ហើយក៏ភិតភ័យតក្កមា សាកសួរពួករាជបុរសទាំងនោះ" ឯពួករាជបុរស ក៏បាននិយាយតបទៅវិញថា "អ្នកទាំងឡាយចូរកុំភិតភ័យអ្វីឡើយ, ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានធ្វើឲ្យក្សេមក្សាន្តស្រេចហើយ" ទើបនាំគ្នាប្រាប់ដំណឹងដោយសព្វគ្រប់ ៗ លំដាប់នោះ ក្រុងអាឡាវីទាំងស្រុងក៏ឮស្នូរសំឡេងសព្ទសាធុការថា "សាធុ! សាធុ!" ដូច្នេះ ចំពោះទៅរកយក្សដ៏អឹកធឹកកងរំពងឡើង, ឯយក្សកាលបើដល់វេលាដែលព្រះដ៏មានព្រះភាគស្តេចទ្រង់ទៅបិណ្ឌបាតហើយ ក៏កាន់បាត្រនឹងចីវរជូនព្រះដ៏មានព្រះភាគទៅបានពាក់កណ្តាលផ្លូវ ហើយទើបត្រឡប់មកវិញ ៗ លំដាប់នោះ ព្រះដ៏មានព្រះភាគស្តេចទ្រង់ចូលទៅបិណ្ឌបាតក្នុងក្រុងអាឡាវី បានស្រេចហើយ ក៏ទ្រង់ធ្វើភត្តកិច្ចរួចស្តេចមក

គង់នៅលើពុទ្ធាសនៈដ៏ប្រសើរ ដែលគេក្រាលថ្វាយទៀបដើមឈើ១ដើម ក្នុងទីដ៏ស្ងាត់ជិតទ្វារនៃនគរ ។

លំដាប់នោះ ព្រះបរមក្សត្រនិងពួកអ្នកនគរ មួយអន្លើដោយពពួកមហាជន ទើបនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ អង្គុយហោមរោមជុំវិញ ហើយក្រាបបង្គំទូលសួរថា «បពិត្រព្រះអង្គដ៏ចំរើន ដូចម្ដេចក៏ព្រះអង្គទ្រង់ទូន្មានយក្សកំណាចកាចអាក្រក់យ៉ាងនេះបាន» ។ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ប្រាប់មហាជនទាំងនោះថា «យក្សកំណាចនោះ បានធ្វើកលមានចម្បាំងជាដើម បានបង្អុរភ្លៀងទាំង ៩ ប្រការ បានធ្វើកលគួរឲ្យខ្លាចឲ្យតក់ស្លុត ហើយសួរនូវប្រស្នាយ៉ាងនេះ ៗ តថាគតក៏បានវិសជ្ជនាប្រាប់យក្សនោះយ៉ាងនេះ» ហើយក៏ទ្រង់សំដែងអាឡវកសូត្រនោះម្ដងទៀត; លុះចប់ធម៌ទេសនាហើយ ពពួកមហាជនចំនួន ៨៤.០០០ នាក់ក៏បានសម្រេចមគ្គផលទាំងអស់គ្នា ។ ទើបព្រះបរមក្សត្រនិងពួកអ្នកនគរបានកសាងទីកន្លែងឲ្យយក្សនៅ ជិតកន្លែងនៃស្ដេចវេស្សវណមហារាជ ទាំងបានធ្វើគ្រឿងសក្ការបូជា មានកម្រងផ្កានិងគ្រឿងក្រអូបជាដើម អស់កាលជានិច្ច; ឯព្រះរាជកុមារនោះ លុះធំដឹងក្ដីឡើងកាលណា ពួករាជបុរសបានក្រាបទូលថា «ព្រះអង្គដែលបានគង់ព្រះជន្មាយុនៅនេះ ក៏ដោយសារព្រះដ៏មានព្រះភាគ ដូច្នេះ សូមព្រះអង្គ

ចូលទៅរកព្រះដ៏មានព្រះភាគនឹងភិក្ខុសង្ឃចុះ» ហើយក៏បញ្ជូនព្រះរាជកុមារនោះ ឲ្យទៅគាល់ព្រះដ៏មានព្រះភាគ ។ ឯព្រះរាជកុមារនោះ លុះបានចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគនឹងភិក្ខុសង្ឃ មិនយូរប៉ុន្មាន ក៏បានសម្រេចដល់អនាគាមិផល បានរៀនពុទ្ធវចនៈចេះចប់សព្វគ្រប់ មានឧបាសកចំនួន ៥ រយនាក់ហែហមជាបរិវារ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់លើកព្រះរាជកុមារនោះឲ្យជាឯតទគ្គៈថា « ម្នាលភិក្ខុទាំងឡាយ បណ្ដាសាវកទាំងឡាយរបស់តថាគត ដែលជាអ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុទាំង ៤ នោះ ឥតមានសាវកដទៃទៀតទេ មានតែហត្ថកអាឡវកៈនេះឯង ដែលប្រសើរជាងគេទាំងអស់ ក្នុងចំណោមសង្គហវត្ថុ » ។

អាឡវកសូត្រព្រមទាំងអដ្ឋកថាចប់តែប៉ុណ្ណេះ ។

